00908377 E1/188.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-May-2013, 12:16
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី១៧៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវណ្ណី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

កញ្ញា សុង ឆវិន្ទ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោកស្រី បេនី យេ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក លឹម សាត (TCW-389) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក លឹម សាត** (TCW-389)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ទំព័រ ១
សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ទំព័រ ៣២
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................................ទំព័រ ៣៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយសម្រាប់សវនាការនៅព្រឹកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី លឹម សាត ដោយភាគីមេធាវីការពារក្ដីទាំងពីរក្រុម។

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ភាគីទាំងអស់!

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សួស្ដីលោកសាក្សី ខ្ញុំចង់សួរសំណួរទៅកាន់លោកមួយចំនួនបន្ថែមទៀតពាក់ព័ន្ធទៅនឹងហេតុការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ និងថ្ងៃក្រោយៗមកទៀត។ លោកសាក្សី តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ អំពីការវាយប្រហារចុងក្រោយលើបន្ទាយទួលពោធិ៍ជ្រៃ? តើការវាយប្រយុទ្ធចុងក្រោយលើបន្ទាយទួលពោធិ៍ជ្រៃនេះ ចាប់ផ្ដើមនៅពេលណាដែរ?

[០៩:០៣:០៩]

**លោក លឹម សាត៖**

**ឆ៖** បាទ ប្រយុទ្ធដែលពេលក្រោយនោះ ដាច់ឆ្នាំ៧៤ ចូល៧៥ ហ្នឹងចុងក្រោយបំផុតហើយប្រយុទ្ធយកផ្ដាច់ព្រាត់មកភូមិទួលជ្រៃ។

**ស៖** តើលោកនៅចាំទេ ការវាយប្រយុទ្ធចុងក្រោយលើបន្ទាយទួលពោធិ៍ជ្រៃនោះចាប់ផ្ដើមនៅក្នុងថ្ងៃណាដែរ តើនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ឬក៏ថ្ងៃណាមួយដែរ?

**ឆ៖** បាទ អត់បានចាំថ្ងៃទេ បើចាំឆ្នាំអាចបានចាំ។

**ស៖** តើវាអាចទេ ដែលថាថ្ងៃវាយប្រយុទ្ធលើបន្ទាយហ្នឹងចុងក្រោយហ្នឹងគឺនៅថ្ងៃ១៧ ខែមេសា

ឆ្នាំ៧៥?

**ធ៖** ខ្ញុំប្រយុទ្ធសមរភូមិទួលពោធិ៍ជ្រៃហ្នឹងគឺក្នុងឆ្នាំ១៩៧៥ តែដែលមុនពេលថ្ងៃទី១៧ មេសាហ្នឹង ខ្ញុំប្រយុទ្ធហើយ តែមិនបានទទួលជ័យជម្នះ គ្រាន់តែ -- ដល់ថ្ងៃទី១៧ មេសា ដែលបានបែកទីក្រុងភ្នំពេញ ហើយខ្ញុំចូលក្រោយគេទៀត។ ចូលម៉ោងដប់ តែគេណោះចូលម៉ោងប្រាំបួន ខ្ញុំចូលម៉ោងដប់ព្រឹក។ វាខុសត្រូវគ្នាម៉ោង។

**ស៖** នៅពេលនេះ ខ្ញុំសូមសួរអ៊ីចេះវិញលោកសាក្សី។ នៅក្នុងពេលណាដែរ ដែលទាហាន លន់ នល់ ឈរជើងនៅបន្ទាយទួលពោធិ៍ជ្រៃនោះ ចុះចាញ់? តើនៅពេលណាដែរ?

**ធ៖** ពេលថ្ងៃ១៧មេសា ហ្នឹងហើយ អត់មានពេលណាទៀត មានពេលថ្ងៃហ្នឹងតែម្តង។ ព្រោះអីខាងភ្នំពេញចូលម៉ោងប្រាំបួន ហើយខ្ញុំកាលណោះយឺតពេល ហើយក៏ចូលម៉ោងដប់ ឬមួយម៉ោងដប់មួយ។ ហ្នឹងខុសម៉ោងគ្នាតែហ្នឹងទេ ថ្ងៃ១៧ មេសា ដូចគ្នា។

[០៩:០៦:១១]

**ស៖** តើលោកអាចជម្រាបអង្គជំនុំជម្រះបន្ថែមដែរឬទេ តើទាហាន លន់ នល់ នោះ ចុះចាញ់យ៉ាងម៉េចទៅ? បានន័យថា នៅពេលនោះ គឺលើកដៃឡើងជាការបញ្ជាក់នូវការចុះចាញ់ ឬក៏គេបង្ហាញយ៉ាងម៉េច ទើបដឹងថាចុះចាញ់នោះ?

**ធ៖** បាទ គេបង្ហាញការចុះចាញ់ គេលើកទង់សទៅណា។ លើកទង់ជ័យស គ្រប់បន្ទាយទាំងអស់។ បានន័យថា គេចុះចាញ់ ដាក់អាវុធហើយ។

**ស៖** លោកឃើញហេតុការណ៍ហ្នឹងផ្ទាល់ភ្នែក បានន័យថា ឃើញទង់ជ័យសហ្នឹង គេលើកពីបន្ទាយហ្នឹង ដោយខ្លួនឯងផ្ទាល់ភ្នែក ឬក៏យ៉ាងម៉េច?

**ធ៖** បាទ ខ្ញុំឃើញផ្ទាល់ ហើយមានលើកនៅកន្លែងបន្ទាយ ហើយមានកាន់មួយទៀត ទៅទទួលខ្ញុំពីសមរភូមិមុខ នៅខាងក្រៅបន្ទាយទៀត។ នាំប្អូនប្រាំនាក់ គាត់ទទួលនាយទាហាន ទៅយកខ្ញុំពីក្នុងមកវិញ ពីក្រៅមកចូលក្នុងទៀត កាន់ទង់សទៅទៀត។

**ស៖** នៅពេលនុ៎ងនោះ នៅពេលដែលលោកឃើញទាហានហ្នឹង លើកទង់ជ័យស តើលោកអាចស្មានទេ មានទាហាននៅទីនុ៎ងហ្នឹងប៉ុន្មាននៅជុំវិញបន្ទាយ និងនៅជុំវិញបន្ទាយទួលពោធិ៍ជ្រៃនោះ តើស្មានមើល ទាហានប្រហែលប៉ុន្មាននាក់?

[០៩:០៧:៥៣]

E1/188.1

**ឆ៖** ខ្ញុំថា តាមខ្ញុំស្មាន ទាហានចំនួនតែ១០០ទេ ហើយប៉ុន្តែយើងកងកុម្ម៉ង់ដូ វាច្រើនដែរ ជុំវិញបន្ទាយទាហានហ្នឹងដែរ តែកងកុម្ម៉ង់ដូ។ ហ្នឹង ការស្មានរបស់ខ្ញុំទេ។

**ស៖** ខ្ញុំយល់ តើលោកចាំទេ ទាហានហ្នឹងស្លៀកពាក់យ៉ាងម៉េចដែរ? ស្លៀកពាក់សម្លៀកបំពាក់ទាហាន ឬក៏ស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលធម្មតា?

**ឆ៖** បាទ ដែលទាហាន និងស៊ីវិល ឬមួយកុម្ម៉ង់ដូនោះខុសគ្នាឆ្ងាយ។ ទេ ខោអាវគេទាហានតឹនុយទាហាន ហើយយើងខទាហារណ៍ដូចកុម្ម៉ង់ដូ ស៊ីវិលធម្មតា យើងដូចប្រជាជនយើងអ៊ីចឹង។ អាហ្នឹងហៅកុម្ម៉ង់ដូ ដែលទាហាន គេតឹនុយជាទាហានផ្សេង។

[០៩:០៩:០១]

**ស៖** នៅពេលដែលពួកគេចុះចាញ់ តើមានអ្វីកើតឡើងចំពោះក្រុមទាហានទាំងអស់ហ្នឹង និងក្រុមកុម្ម៉ង់ដូនោះ?

**ឆ៖** អត់មានអីកើតឡើងផង។ ពួកខ្ញុំ ជាមួយពួកគេហ្នឹង រស់នៅជាមួយគ្នាអ៊ីចឹង ប្រមូលអាវុធអីដាក់គរហ្នឹងទៅ ហើយពួកខ្ញុំប្រជុំជួរជាមួយគេអ៊ីចឹងទៅ គេប្រជុំជួរជាមួយផ្សេង គេផ្សេងទៅ ប៉ុន្តែគេដកអាវុធដាក់គរដោយឡែកអ៊ីចឹងទៅ ហើយពួកខ្ញុំនៅអាវុធហ្នឹងដៃ នៅប្រជុំជួរដូចគ្នាអ៊ីចឹងទៅ ហើយមេគេ គេរៀបចំ មេកុម្ម៉ង់ដូ មេទាហានអី គេរៀបចំផ្នែកៗគ្នាគេទៅ ហើយពេលអ៊ីចឹងទៅ ខ្ញុំធ្វើដំណើរចេញមកភូមិពោធិ៍មកទៀត មកលើទៀត។

**ស៖** តើលោកដឹងទេ តើរយៈពេលប៉ុន្មានដែរ ដែលទាហាន និងកុម្ម៉ង់ដូមកពីបន្ទាយហ្នឹងនៅជួបជុំគ្នា? តើនៅជួបជុំគ្នារយៈពេលប៉ុន្មានដែរ ទើបបែកគ្នានោះ?

**ឆ៖** អារឿងហ្នឹង ខ្ញុំអត់បានដឹងដែរ ខ្ញុំឡើងមក ចេះតែឡើងជាបន្តបន្ទាប់មកឡើង ទាល់តែដល់សាលាខេត្តពោធិ៍សាត់បណ្តោយ។ មកដេកផ្លូវមួយយប់បានឡើងមកដល់ខេត្តៗឡើងមកស្រុកក្រគរវិញ។ មិនដឹងជាគេបែកជួរជាពេលម៉ាន ថ្ងៃរម៉ានៗ ខ្ញុំអត់បានដឹងទេ។

[០៩:១០:៤៣]

**ស៖** តើលោកឮពីគេ ពីឯង ពីទាហានដូចគ្នាពីខាងលោកនោះ តើធ្លាប់ឮដែរឬទេ? ថាតើក្រុមទាហាន លន់ នល់ និងកុម្ម៉ង់ដូហ្នឹងទៅដល់ទីរួមខេត្តនោះ ពោធិ៍សាត់ហ្នឹងដោយរបៀបណាដែរ? លោកធ្លាប់ឮពីគេទេ?

**ឆ៖** ខ្ញុំទៅតែពួកខ្ញុំតើ។ ពួកដែលទាហានកុម្ម៉ង់ដូ គេនៅដោយឡែកគ្នាគេដែរទៅ ទៅតាមបន្ទាយ

ទីតាំងគេទៅ។ ខ្ញុំចេះតែឡើងតែមកលើរហូតមក។

[០៩:១១:៣២]

**សះ** ខ្ញុំសំណួររបស់ខ្ញុំ គឺចង់សួរថាតើនៅពេលនោះ ឬក្រោយមកនោះ តើលោកបានឮពីគេពីឯងដែរឬទេ? ទាហាន ក្រុមទាហានដែលចុះចាញ់នោះចាកចេញពីបន្ទាយ ហើយធ្វើដំណើរទៅសាលាខេត្តនោះដោយរបៀបណាដែរ? តើលោកមានឮពីគេ ពីឯងទេក្រោយមក ឬក៏នៅពេលនោះ គេមានឮពីគេពីឯងទេទៅដល់សាលាខេត្តដោយរបៀបណា?

**ឆះ** ខ្ញុំអត់បានឮពីគេពីឯង គិតតែនាំគ្នាធ្វើដំណើរចេញទៅបន្តទៀត។ មកដល់សាលាខេត្តហ្នឹងចេញមកពីខេត្តហ្នឹង មកស្រុកក្រគរ ពីកើតទៅទៀត។ ឡើងឡានមកទៅស្រុកក្រគរណោះទៀត។

**សះ** តើលោកបានឮពីក្រុមទាហានរបស់លោកដូចគ្នា ឬក៏ក្រោយមកនោះ តើលោកឮទេថាក្រុមទាហានហ្នឹងនៅតែស្លៀកសម្លៀកបំពាក់ទាហានដដែល ឬក៏គេឲ្យដូរសម្លៀកបំពាក់ស៊ីវិលវិញ?

**ឆះ** បញ្ហាហ្នឹងគេអត់ឲ្យដូរទេ គឺមិនឲ្យច្រឡូកច្រឡំនឹងកុម្មុំង់ដូ នឹងមួយប្រជាជន។ យើងទាហាននៅទាហានដដែល។ សម្លៀកបំពាក់នៅដដែលតើ។

**សះ** តើលោកដឹងដែរឬទេ ថាតើក្រុមទាហានហ្នឹងនៅពេលទៅដល់សាលាខេត្ត តើគេឲ្យនៅម្តុំរួមគ្នាដែរឬទេ? បានន័យថានៅពេលដែលចេញពីបន្ទាយទៅដល់សាលាខេត្តហ្នឹង គឺគេឲ្យដើរទៅម្តុំជាមួយគ្នា ឬក៏អនុញ្ញាតឲ្យដើរបើកចេញទៅណាផ្សេងបាន?

**ឆះ** បាទ ខ្ញុំក្តាប់អត់បាន អត់យល់ទេ។ ទាហានផ្សេង ពួកខ្ញុំផ្សេង។ ដល់តែថាឲ្យទាហានទៅសម្រាកនៅសាលាខេត្ត ឬមួយពួកខ្ញុំអត់ទេ។ ហើយសូមបញ្ជាក់ម្តងទៀតមក។

[០៩:១៤:០៤]

**សះ** តើលោកដឹងដែរឬទេ ដោយសារតែលោកបានឃើញ និងបានឮ តើលោកដឹងថាតើក្រុមទាហាន លន់ នល់ ផ្សេងទៀតនោះ ឬក៏បានន័យថាក្រុមទាហាន លន់ នល់ ពី មកពីខេត្តពោធិ៍សាត់ហ្នឹង គឺថាត្រូវគេបញ្ជូនទៅសាលាខេត្តហ្នឹងរួមគ្នា ឬក៏គេបញ្ជូនទាហាន លន់ នល់ ពីទួលពោធិ៍ជ្រៃតែនៅម្តុំនោះទេទៅសាលាខេត្ត តើមានមកផ្តុំពីខេត្តផ្សេងទៀតបញ្ជូនទៅសាលាខេត្តរួមគ្នាដែរឬទេ?

**ឆះ** អត់មានបញ្ជូនទៅណាទេ។ ដល់ថ្ងៃណាខ្ញុំចូលមកគឺកន្លែងណា នៅកន្លែងហ្នឹងដដែល។ ទីតាំងកន្លែងណាដូចពោធិ៍ជ្រៃ ក៏នៅពោធិ៍ជ្រៃ ភូមិពោធិ៍ក៏នៅភូមិពោធិ៍។ ហើយមកដល់កន្លែងខេត្តហ្នឹងជុំវិញសាលាខេត្តហ្នឹងក៏នៅតាមអង្គភាពគេហ្នឹងទៅ។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់លាស់ខ្ញុំសូមអធ្យាស្រ័យ។ ខ្ញុំចង់សួរអំពីទាហាន លន់ នល់។ យើងដឹងហើយថាមានក្រុមទាហាន លន់ នល់ មួយក្រុមនោះគឺគេបញ្ជូនពីទួលពោធិ៍ជ្រៃទៅសាលាខេត្ត ហើយតើលោកដឹងទេថាមានក្រុមទាហាន លន់ នល់ ហ្នឹងពីកន្លែងផ្សេងៗនៅក្នុងខេត្តពោធិ៍សាត់ត្រូវបាន គេបញ្ជូនពីទីកន្លែងនោះរួមជាមួយគ្នាទៅសាលាខេត្តពោធិ៍សាត់ដែរ? តើលោកដឹងទេ?

**ឆ៖** អត់មាននរណាបញ្ជូនទៅសាលាខេត្តផង។ នៅតែកន្លែងទីតាំងគេទាំងអស់។

[០៩:១៦:០០]

**ស៖** នៅពេលមួយនោះគឺលោកឈរជើងនៅកន្លែងកុងត្រូល ភូមិពោធិ៍នៅជិតម្តុំៗហ្នឹង តើលោក តើអានេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ បើលោកសួរខ្ញុំអ៊ីចឹងច្រាសបណ្តោយអ៊ីចឹង។ ព្រោះខ្ញុំត្រឡប់មកពីស្រុកក្រគរវិញ គេ ប្រមូលទាហានទៅពោធិ៍ជ្រៃវិញ បានខ្ញុំទៅឈរជើង។ តែពេលខ្ញុំឡើងថ្ងៃ១៧មេសា ខ្ញុំឡើងបង្ហួសទៅ បង្ហួតបាត់ហើយ។ បាទ ខ្ញុំពិបាកឆ្លើយដែរ។

**ស៖** ប្រហែលខ្ញុំយល់លោកខុស។ ខ្ញុំយល់ថាក្រោយពីការកាន់កាប់បន្ទាយភូមិ -- បន្ទាយទួល ពោធិ៍ជ្រៃនោះ គឺលោកបានឈរជើងនៅផ្លូវបំបែក ឬក៏កន្លែងដែលថាភូមិពោធិ៍ តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា។

[០៩:១៧:២២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំទៅនឹងសំណួររបស់មេធាវីនោះគឺថា មេធាវី មិនបញ្ជាក់ពេលវេលាឲ្យបានជាក់លាក់។ គាត់សួរអំពីអំឡុងថ្ងៃ ១៧ មេសា ក៏ប៉ុន្តែនៅពេលនេះគឺថាគាត់ សួរអំឡុងពេលផ្សេងទៅវិញ ដូច្នេះហើយទើបឲ្យមានការយល់ច្រឡំ។ សូមឲ្យមេធាវីនេះសួរបញ្ជាក់ ពេលវេលាឲ្យបានច្បាស់លាស់ដើម្បីឲ្យសាក្សីនេះយល់ឲ្យច្បាស់និងឆ្លើយមកវិញ។ ហើយការដែលយើង សួរជាក់លាក់ទៅលើពេលវេលានេះគឺឲ្យសាក្សីឆ្លើយជាក់លាក់តបមកវិញផងដែរ។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំឯកភាពជាមួយនឹងតំណាងសហព្រះរាជអាជ្ញា ក៏ប៉ុន្តែខ្ញុំមានវិធីរបស់ខ្ញុំក្នុងការតាំងសំណួរនៅ ពេលដែលខ្ញុំផ្តោតទៅលើអង្គហេតុហ្នឹងគឺថា ខ្ញុំចង់សួរអ៊ីចេះ។

[០៩:១៨:០៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដឹងទេ ឬក៏លោកនៅចាំដែរឬទេ លោកបានធ្វើដំណើរទៅណាទៀត ក្រោយពីទាហាន លន់ នល់ ត្រូវបានចុះចាញ់ និងត្រូវបានឡោមព័ទ្ធឱ្យនៅម្តុំនោះ?

**លោក លឹម សាត៖**

**ឆ៖** បាទ ខ្ញុំជម្រាបលោកអ៊ីចឹងដែរថា ខ្ញុំឡើងបន្តបន្ទាប់មករហូតមកដល់សាលាខេត្តហ្នឹងបាន ខ្ញុំចេញទៅស្រុកក្រគរទៀតដែរ។

**ស៖** តើលោកចាំទេ ពេលណាដែរជាក់លាក់នោះ? នៅពេលដែលលោកឃើញឡានដឹកទាហាន លន់ នល់ ធ្វើដំណើរចេញពីបន្ទាយទួលពោធិ៍ជ្រៃនោះសំដៅទៅសាលាខេត្ត តើពេលណាឱ្យច្បាស់ និង ជាក់លាក់? តើលោកនៅចាំទេ?

**ឆ៖** អត់ទេ សួរខ្ញុំអ៊ីចឹងអត់ត្រឹមត្រូវ។

**ស៖** សូមឱ្យលោកកែទៅ ប្រសិនថាខ្ញុំសួរមិនត្រឹមត្រូវ លោកពន្យល់កែត្រង់ចំណុចហ្នឹងទៅ។

**ឆ៖** មានទាហានដឹកពីសាលាខេត្តមកទួលពោធិ៍ជ្រៃ ដល់ដឹកពីពោធិ៍ជ្រៃទៅសាលាខេត្តវិញ អត់មានទាហានណាដឹកទៅ។ ហើយអាហ្នឹងខ្ញុំឆ្លើយថាម៉េចទៅវិញទៅ?

**ស៖** ខ្ញុំយល់លោកសាក្សី។ ក៏ប៉ុន្តែខ្ញុំព្យាយាមចង់សួរលោក តើលោកដឹងទេ ថាតើគេដឹកទាហាន លន់ នល់ នោះពីបន្ទាយទួលពោធិ៍ជ្រៃទៅសាលាហ្នឹងដោយរបៀបណា? ខ្ញុំចង់សួរ តើដឹងទេ ដឹកដោយរបៀបណាពីបន្ទាយពីទួលពោធិ៍ជ្រៃទៅសាលាខេត្ត?

**ឆ៖** ខ្ញុំមិនដឹងឆ្លើយថាម៉េចទេ បើថាខ្ញុំដឹងតែដឹកពីសាលាខេត្តមកបន្ទាយពោធិ៍ជ្រៃ។

[០៩:២០:៣៩]

**ស៖** ខ្ញុំយល់លោកសាក្សី ក៏ប៉ុន្តែនៅពេលនោះគឺគេក្រុមទាហាន លន់ នល់ ហ្នឹងគឺនៅទួលពោធិ៍ជ្រៃ ហើយក្រោយមកយើងឃើញនៅសាលាខេត្តដែរ។ ខ្ញុំគ្រាន់តែចង់សួរលោកតែប៉ុណ្ណោះ តើលោកដឹងដែរឬទេ ថាតើគេដឹកទាហានពីភូមិបន្ទាយទួលពោធិ៍ជ្រៃហ្នឹងទៅសាលាខេត្តនេះដោយរបៀបណា? តើលោកដឹងទេ? ហើយលោកបានឃើញដែរឬទេ?

**ឆ៖** បញ្ហាដឹកពីពោធិ៍ជ្រៃទៅសាលាខេត្ត ខ្ញុំអត់បានឃើញ អត់បានដឹងទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ លោកក៏មិនបានឃើញក្រុមទាហាន លន់ នល់ ពីកន្លែងផ្សេងៗទៀត

នៅក្នុងខេត្តពោធិ៍សាត់នោះត្រូវបានគេដឹកបញ្ជូនទៅសាលាខេត្តដើម្បីជួបប្រជុំដែរ លោកក៏មិនបានឃើញដែរ តើអ៊ីចឹងមែនទេ?

[០៩:២១:៥៣]

**ឆ៖** បាទ ខ្ញុំអត់បានឃើញគេទេ បើឃើញ ឃើញតែខ្ញុំទៅឈរជើងនៅក្បែរភូមិពោធិ៍វិញ។ ព្រោះអីខ្ញុំនៅឯស្រុកក្រគរអីណោះ ខ្ញុំអត់បានដឹងនឹងគេផង វាខុសគ្នាឆ្ងាយ។

**សៈ** លោកសាក្សី នៅពេលនេះយើងត្រឡប់ទៅពេលវេលាមួយដែលលោកថាបានឃើញឡានហ្នឹងដឹកទាហាន លន់ នល់ នោះជិះឆ្លងកាត់ នៅពេលនោះលោកឃើញ។ កាលពីម្សិលមិញលោកបានឆ្លើយថា លោកឃើញឡានហ្នឹងប្រហែល១០ទៅ១៥ឡានបើកកាត់លោក ហើយឡានទាំងអស់ហ្នឹងឃើញមានមនុស្សអង្គុយនៅលើឡាននុំង។ លោកកាលពីយប់មិញលោកបានគេង ប្រហែលជាលោកអាចគិតព័ត៌មានបន្ថែមទៅលើចំណុចនេះ។ តើលោកប្រាកដទេថា ឡានដែលលោកបានឃើញហ្នឹងគឺមានចំនួនឡានប្រហែលជា១០ទៅ១៥ឡាន? តើលោកបានប្រាកដទេ?

[០៩:២៣:០៧]

**ឆ៖** បញ្ហាហ្នឹងគឺវាយូរឆ្នាំដែរ មើល៍! តាំងពី៧៥រហូតដល់២០១៣ វាច្រើនភ្លេចភ្លាំងណាស់ដែរ ប៉ុន្តែដឹងថាគេដឹកជញ្ជូនទាហានមិនមានឋានន្តរសក្តិយកទៅទួលពោធិ៍ជ្រៃ ហើយខ្ញុំស្មានដែលដឹកប្រាំឡានហ្នឹងវាស្មាន ខ្ញុំថាមិនត្រឹមត្រូវទេ។

**សៈ** តើមានឡាន១០, ១១, ១២ ឬក៏១៣? តើលោកដឹងទេ?

**ឆ៖** បើខ្ញុំស្មានថា ១៥ខុសហើយ ខ្ញុំមិនដឹងថាម៉េច វាមានតែខ្ញុំស្មានខុស ព្រោះអីអាលែច្របូកច្របល់។ គេយកពីក្រោមមក ខ្ញុំមិនបានទៅពិនិត្យផង។

**សៈ** ចំណុចនេះខ្ញុំមិនយល់ទេលោកសាក្សី កាលពីម្សិលមិញលោកបានផ្តល់សក្ខីកម្មឆ្លើយថា លោកឃើញឡាន១០ទៅ១៥។ កាលពីមុនលោកឆ្លើយប្រាប់ចៅក្រមថា ប្រហែលជា៣០ឡាន ហើយពីម្សិលមិញលោកបញ្ជាក់ច្បាស់ណាស់ថា ឃើញ១០ -- ឡាន១០ ទៅ១៥ឡាន ហើយនៅពេលនេះតើលោកនិយាយថាលោកអត់ធ្លាប់ឃើញឡានហ្នឹងទេ ឬក៏ខ្ញុំស្តាប់លោកឆ្លើយខុស ថាមិនមែនឆ្លើយអ៊ីចឹងទេ?

[០៩:២៤:៥៦]

**ឆ៖** ខ្ញុំបានដឹងថា ១៥ឡានមែន ប៉ុន្តែខ្ញុំអាឡានទៀតៗ ខ្ញុំវាអាលែច្របូកច្របល់ដែរ មានទៅចាំ

ប្រាកដអីច្បាស់លាស់។ ថាឡានមកប៉ុន្មានៗអីទៀតណ៎ា ព្រោះអីខ្ញុំនៅផ្ទាល់ហ្នឹងដឹងថា១៥ឡាន ហើយអាលែទៅនេះទៅណោះ មិនដឹងគេឡានមកប៉ុន្មានៗទៀត។ ហើយខ្ញុំមានបានបញ្ជាក់ពួកខ្ញុំអីទៀតផង។

**ស៖** សូមអរគុណលោកសាក្សី។ តើលោក តាមការចងចាំរបស់លោកនេះ តើលោកអាចរៀបរាប់ប្រាប់យើងខ្ញុំដែរឬទេ ឡានហ្នឹងឃើញជាឡានប្រភេទអ្វីដែរនៅពេលដែលលោកឃើញនោះ?

**ឆ៖** បាទ ឡានប្រភេទឡាន ពួកអាឡានទ័ព អាសេ.អឹម.សេ គេហ្នឹង អាកង់១០ហ្នឹង ហើយនិងពួកអាឡានសំណាញ់ គេហៅឡានសំណាញ់ ឡានទ្រុងឡានសំណាញ់ហ្នឹង។ ហើយអាឡានអង្គរគេហ្នឹងមានបីប្រភេទហ្នឹង។ ឡានអង្គរៗហ្នឹង ប៉ុន្តែខ្ញុំមិនសូវស្គាល់ទេ គ្រាន់តែឮគេថា។

[០៩:២៦:១៥]

**ស៖** តើឡានទាំងអស់ហ្នឹងគឺជាឡានទាហាន ឬក៏ជាប្រភេទឡានស៊ីវិលដែរ? នៅក្នុងក្បួនឡានហ្នឹង តើលោកឃើញឡានទាហាន ឬក៏ជាឡានស៊ីវិលផងដែររួមជាមួយគ្នា?

**ឆ៖** បាទ ឡានទាហានតិចជាងឡានស៊ីវិល យកឡានប្រជាជនដឹក យកឡានដូចអាឡានសំណាញ់ដឹកជញ្ជូនស្បៀង ឡានដឹកសម្ភារៈអីគេផ្សេងៗហ្នឹង អាឡានៗឯកជនគេទេ។ ដល់ឡានទាហានឡាន មានអាឡានសេ.អឹម.សេ អាកង់១០ហ្នឹង ពីរបីគ្រឿង។

**ស៖** តើលោកអាចនៅចាំទេ តើឡានស៊ីវិលនោះប៉ុន្មានឡាន? ហើយឡានទាហានហ្នឹងប៉ុន្មាន? ពាក់កណ្តាលម្នាក់ ឬក៏ឡានទាហានមួយភាគបីនៃឡានស៊ីវិលឬក៏យ៉ាងម៉េច ឬក៏ឡានហ្នឹងចំនួនប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនបានចាំទេ ប៉ុន្តែការស្មានឡានទាហានតិចជាង ដូចថាឡានទាហានតែប្រាំប្រាំមួយអីចឹងទៅ ផុតពីហ្នឹងឡានប្រជាជនទាំងអស់។

[០៩:២៧:៤១]

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ នៅពេលដែលលោកនិយាយថា មិនត្រឹមតែមានឡានទាហានទេ ក៏មានឡានស៊ីវិល។ បានន័យថា ឡានស៊ីវិលហ្នឹង ខាងក្រោយគេ គេឃ្លុំជិត ឬក៏យ៉ាងម៉េច?

**ឆ៖** គេអត់ឃ្លុំជិតផង។ បើកចំហទាំងអស់ហ្នឹង ព្រោះអីក្តៅ។ អត់មានឃ្លុំអីទេ។

**ស៖** តើឡានគ្របហ្នឹងទាំងអស់ ឬក៏យ៉ាងម៉េចនៅពេលដែលលោកឃើញហ្នឹង? តើលោកឃើញកន្ទុយក្រោយឡានហ្នឹង ឃើញគ្រប់ឡានទាំងអស់ឬក៏យ៉ាងម៉េច?

**ឆ៖** ឡានគេអត់គ្របទេ។ អត់មានឡានណាគ្របទេ។ មនុស្សនៅឈរច្រងហ្នឹង។ មានឡានណាគ្រប។

[០៩:២៨:៤៩]

**ស៖** អ្នកដែលលោកបានឃើញឈរលើឡានទុំង តើអ្នកទាំងអស់ទុំងស្លៀកពាក់ជាយោធា ជាទ័ព ឬក៏ស្លៀកពាក់យ៉ាងម៉េចដែរ?

**ឆ៖** សុទ្ធពួកទាហានគេស្លៀកពាក់ទាហានហើយ។ សុទ្ធតឹនុយទាហានទាំងអស់។ រ៉េកុម្ម៉ង់គេទាហានស្បែងជើងគេសុទ្ធស្បែងជើងទាហានហើយ។ មានវ៉ាឡូអីទៅតាមខ្លួនទាំងអស់។

**ស៖** តើលោកមានឃើញអ្នកនៅឈរលើឡានហ្នឹងជាជនស៊ីវិលដែរឬទេ?

**ឆ៖** អត់មានទេ អត់មានច្របូកច្របល់អីទេ។ អត់មានស៊ីវិលអីទៅជាមួយទេ។ គេប្រកាសតែទាហាន នាយទាហានដែលមានឋានន្តរសក្តិហ្នឹង។ បើអត់ឋានន្តរសក្តិអត់មានសិទ្ធិទៅទេ។

**ស៖** ដូច្នេះឡានដែលលោកបានឃើញបើកពីសាលាខេត្តទៅបន្ទាយទួលពោធិ៍ជ្រៃនោះ គឺលោកឃើញសុទ្ធតែស្លៀកពាក់ទាហានទាំងអស់ ហើយមានអ្នកខ្លះនោះមានពាក់បណ្តាស័ក្តិផងដែរ ហើយនិងមានវ៉ាឡូទៅជាមួយផងដែរ?

**ឆ៖** បាទ គេអ្នកខ្លះគេពាក់ស័ក្តិទៅហើយ ហើយអីវ៉ែអីវ៉ាន់គេថាឲ្យទៅរៀនទៅស្ងួត្រមិនយកអីវ៉ែអីវ៉ាន់ទៅ ខោអាវអីយកទៅ។ ហ្នឹងគេហៅទៅរៀនទៅស្ងួត្រ ទាំងលោកទាំងខ្ញុំហ្នឹងទៅរៀនទៅស្ងួត្រមានទៅខ្លួនទទេឯណា មានខោអាវទៅហើយ អត់តែកាំភ្លើងទេ។

[០៩:៣០:៥៦]

**ស៖** តើលោកដឹងដោយវិធីណាដែលថា លោកបានឃើញទាហាននោះស្លៀកពាក់ឯកសណ្ឋាននៅលើឡាននោះថាចេញពីសាលាខេត្តទៅៗរៀន ទៅចូលវគ្គសិក្សា តើលោកដឹងដោយរបៀបណា?

**ឆ៖** ដឹងតាមគណៈបញ្ជាការខ្ញុំ។

**ស៖** ខ្ញុំនឹងនិយាយអំពីជនស៊ីវិលវិញ តើលោកបានឃើញជនស៊ីវិលណាដែរឬទេនៅក្នុងឡានធំៗដែលដឹកជាក្បួននេះ ដែលដឹកយោធា? ថាតើមានឃើញជនស៊ីវិលណានៅលាយឡំហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់មានទេ អត់មានស៊ីវិលឯណាទៅជាមួយ មានតែទាហានសុទ្ធបាទ។

**ស៖** តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាតើមានទាហាន យោធាប៉ុន្មាននាក់ដែលជិះនៅលើឡានទាំង១៥ ដែលលោកបានឃើញនោះ? ក្នុងឡាននីមួយៗប្រហែលជាមានប៉ុន្មាននាក់ ទាហាននោះបាទ?

**ឆ៖** ឡានវាមិនកំណត់ដាក់អ្នកដាក់ដែរ អាខ្លះ៣០ទៅ អាខ្លះ៣០ជាងទៅ។ វាមិនកំណត់បាន

ហើយឡានអាធំវាដាក់ចង់ចូល៤០នាក់អីទៅ ហើយឈរជើងជ្រៀតគ្នាទៅ។ ខ្ញុំមិនអាចកំណត់បាន មិនអាចឈរចាប់រាប់ មួយ ពីរ បី ឯណា អត់ផង។ គិតតែថាឲ្យទៅៗ គេឲ្យទៅគឺឲ្យទៅ អ្នកណាឡាននេះមានប៉ុន្មាននាក់ៗ គ្រាន់តែមើលឃើញថា អូ៎! នៅពេញឡានដែរ អា១០នាក់ក៏ពេញ អា២០នាក់ក៏ពេញ ហើយខ្ញុំបានអីពិនិត្យអីចឹងទៅ គេថា អ្នក! គេអូមក ថាអ្ន៎! ឲ្យឆាប់ចេញឡានពីរ! ហើយពួកខ្ញុំឲ្យទៅពីរបាត់ហើយ នៅឡានប៉ុន្មានកាក់នៅទុកនុ៎ងសិនទៅ តែដល់គេតេអូមកទៀតថាឲ្យទៅទៀត ក៏ខ្ញុំឲ្យទៅទៀតទៅ។

[០៩:៣៣:៥៤]

**ស៖** លោកសាក្សី លោកចង់និយាយថា នៅពេលដែលគេបញ្ជូនឡានមួយពីភូមិពោធិ៍ទៅទួលពោធិ៍ជ្រៃហ្នឹងគឺថា សុទ្ធតែជាយោធាដែលមានពាក់ឯសណ្ឋានជាយោធានៅលើឡានហ្នឹង។ តើអីចឹងដែរឬទេ?

**ឆ៖** បាទ គាត់និយាយភាសាខុសគ្នា តែយោធាៗវាយោធាខ្មែរក្រហម។ បាទ ខ្ញុំចង់បញ្ជាក់អីចឹង។ ហើយទាហានគឺទាហាន លន់ នល់ ដល់ថាយោធាឡើងឡានហើយ មានតែយោធាខ្មែរក្រហមវិញអីចឹង។ ខ្ញុំនិយាយថាទាហានៗ លន់ នល់ គេបញ្ជូនទៅតាមផ្លូវដែលខ្ញុំនៅហ្នឹង គឺទាហាន លន់ នល់ បញ្ជូនទៅពោធិ៍ជ្រៃ អត់មានយោធាណាទេ។ យោធាៗមានយោធាខ្មែរក្រហម។ អីចឹងខ្ញុំជម្រាបអីចឹងតែម្តង។

**ស៖** ដើម្បីឲ្យយើងយល់ច្បាស់ ខ្ញុំសួរលោកអំពីមនុស្សដែលជិះនៅលើឡានធំៗនោះ ដែលទើបតែចេញមកពីសាលាខេត្តនោះ តើពួកទាំងនុ៎ងជាទាហាន លន់ នល់ ឬក៏ជាយោធា ដែលជាយោធារបស់ខ្មែរក្រហមខាងលោក កាលនោះ?

**ឆ៖** ពួកខ្ញុំអត់មានទៅជិះឡានអីច្របូកច្របល់ជាមួយគេទេ។ មានតែទាហានៗបណ្តោយ។

[០៩:៣៦:១៤]

**ស៖** នេះហើយជាគំនិតដែលខ្ញុំគិត។ តើលោកច្បាស់១០០ភាគរយដែរឬទេ ថាអ្នកទាំងនោះជាទាហាន លន់ នល់ ដែលស្លៀកពាក់ជាឯកសណ្ឋាន។ តើលោក១០០ភាគរយ ច្បាស់ថាអីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំ១០០ភាគរយដែរ ច្បាស់អីចឹង។ ព្រោះអីយោធាខ្មែរក្រហម វាខោអាវផ្សេងទៅវិញអីចឹង។ ខោអាវផ្សេង ហើយស្បែកជើង កាលណាស្បែកជើងបូ៉ា ឬមួយស្បែកជើងកង់ឡានឯណោះវិញទេ។ ហើយបើទាហានស្បែកជើងម៉ែហ្វកឯណោះ ហើយតីនុយ ហើយគេពាក់ស្លាក ដែគេទៀត។

ដូចណាពាក់ស្លាកអី គេសញ្ញា ពួកអាណាពួកក្បាលខ្លា។ ទាហានវាមានច្រើនប្រភេទគេណាស់។ ពួកក្បាលខ្លា ពួកក្បាលខ្មោច ហ្នឹងហើយ។ អាហ្នឹងគេពាក់នឹងដៃគេនេះ ហើយពួកខ្មែរក្រហមមានអីពាក់ មានតែអាវតេតារ៉ុងខ្មៅ ឬអាវតេតារ៉ុងពណ៌ស្លឹកចេកហ្នឹង។ បានវាខុសគ្នាអ៊ីចឹង។

**ស៖** នៅពេលដែលឡាននោះ ចេញម្តងមួយៗទៅទួលពោធិ៍ជ្រៃ ហើយនៅពេលត្រឡប់មកវិញ ឡានទទេនោះ។ នៅពេលដែលគេបញ្ជូនទៅទួលពោធិ៍ជ្រៃ គេដឹកទាហាន លន់ នល់ ទៅ ដោយមានឯកសណ្ឋានជាទាហានផង តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំថា ទាហានហើយៗ មិនដឹងសួរម៉េចទៀតទេ។ ឯកសណ្ឋានទាហានហើយ។

**ស៖** លោកសាក្សី អ្វីដែលខ្ញុំចង់ឲ្យច្បាស់នោះ គឺថាចង់ឲ្យលោកបញ្ជាក់ថា ពីព្រោះថាសាក្សីមកឆ្លើយកាលពីដើមសប្តាហ៍នេះ គាត់បានពន្យល់តុលាការថា "មនុស្សដែលគេដឹកចេញពីសាលាខេត្តទៅទួលពោធិ៍ជ្រៃនោះ គេដាក់តាមឡាន គេស្លៀកពាក់ជាស៊ីវិលទាំងអស់"។ ហើយគាត់នោះ គាត់ឆ្លើយថា "មិនដែលឃើញមានឯកសណ្ឋានជាទាហាន ឬក៏សញ្ញាស័ក្តិអ្វី បណ្តាស័ក្តិអ្វីទេ"។ ហេតុនេះហើយ បានជាខ្ញុំចង់សួរឲ្យលោកបញ្ជាក់ឲ្យច្បាស់យើងទាំងអស់គ្នា ថាតើលោកឃើញហ្នឹង ជារបៀបម៉េច?

[០៩:៣៩:០៧]

**ឆ៖** ខ្ញុំចង់បញ្ជាក់អ៊ីចេះដោយខ្លីបណ្តោយ ដែលពួកគេធ្វើសកម្មភាពហ្នឹង នៅក្នុងទួលពោធិ៍ជ្រៃ គេយកសម្ភារៈទាហានមកវិញទៀត ដូចជាវ៉ាឡូវ៉ាអី គេយកមកវិញទៀត អត់តែខោអាវក្នុងខ្លួនទេ។ ទាំងពីកាម៉ែល អាកាម៉ែលគេដាំបាយ កាម៉ែលរាងពងក្រពើនោះ។

**ស៖** តើនេះជាចម្លើយរបស់លោកនៅក្នុងសក្ខីកម្ម តើនៅពេលដែលគេសម្លាប់ទាហានទាំងនោះ គឺគេស្លាប់ទាំង -- គេសម្លាប់ទាំងឯកសណ្ឋាន ពេលក្រោយមកបានគេដោះយក ឬក៏ម៉េច តាមចម្លើយរបស់លោកពេលនេះនោះ?

**ឆ៖** អារឿងសម្លៀកបំពាក់គេមិនដោះទេ គេយកតែអាវ៉ាឡូខាងក្រៅទេ។ ដូចជាសម្ភារៈនៅក្រៅខ្លួន ដូចនាឡិកាគេដោះយក។ ដូចថាខោអាវ គេមិនដោះយកទេ។ គេយកតែ ដូចវ៉ាឡូវានៅខាងក្រៅខ្លួន យកកាម៉ែលអីសម្រាប់យកដាំបាយ។ ចុះថាទៅរៀនសូត្រ រៀបចំអីវ៉ែអីវ៉ាន់ទៅហើយ។ ហើយម្ល៉ោះហើយមានអារបស់ខាងក្រៅខ្លួន បើអារបស់ក្នុងខ្លួនអ៊ីចេះជានាឡិកាគេដោះយក។ អាហ្នឹងហើយ ខ្ញុំបានដឹងច្បាស់អ៊ីចឹងម្តង។

[០៩:៤០:៤៩]

**ស៖** តើលោកដឹងដែរឬទេនៅថ្ងៃនោះក៏មានមនុស្សដែលស្លៀកពាក់ជាសម្លៀកស៊ីវិល ក៏ត្រូវបានគេនាំឡូលពោធិ៍ជ្រៃដើម្បីទៅសម្លាប់ចោលដែរនោះ លោកដឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ រឿងហ្នឹងឃើញស៊ីវិលអី អត់មានបានឃើញ ហើយអត់បានដឹងទេ។

**ស៖** សូមលោកគិតបន្តិចឡើងវិញ តើលោកបានឃើញនៅខាងពីក្រោយឡានធំៗនោះ តើលោកអាចឃើញក្នុងចំណោមនោះមានអ្នកណាម្នាក់ ឬក៏មនុស្សប្រហែលប៉ុន្មាននាក់ក្នុងឡានមួយៗដែលថាស្លៀកជាស៊ីវិល មិនមែនស្លៀកជាទាហានទាំងអស់ទេ? លោកគិតបន្តិចមើល តើនៅនឹកឃើញដែរឬទេ?

[០៩:៤១:៥៥]

**ស៖** អត់ទេ អត់ដឹង អត់មានបានឃើញ។

**ឆ៖** តើលោកបានឃើញទេថា មានជនស៊ីវិលណានៅក្នុងឡានជាឡានធម្មតាដែលគេបើកបរទៅកន្លែង -- នៅជាមួយកន្លែងឡានទាហាន កន្លែងឡានយោធាហ្នឹងដែរឬទេ? ថាតើមានឡានជនស៊ីវិលក្រុមជនស៊ីវិលណាមួយណាមួយលាយឡំនៅជាមួយឡានទាហាននៅកន្លែងនោះដែរឬទេ?

**ឆ៖** អត់ទេ អត់មានទេ គឺដាច់ខាតគឺមានតែទាហានម្តង។ អត់មានប្រជាជនអីច្របូកច្របល់។ សូម្បីតែចេញដើរ ទៅកន្លែងមួយៗគឺមាននាទីច្បាស់លាស់ដែរ អត់មានឲ្យច្របូកច្របល់ទេ កំពុងតែគេបញ្ជូនទៅចុះ អត់មាន។ ទាំងប្រជាជន មិនទាំងប៊ានចេញពីផ្ទះផង នៅកន្លែងតាមភូមិដែលភូមិពោធិ៍ហ្នឹង។ ចាប់ពីភូមិពោធិ៍ឡើងលើអត់មាន សឹងមិនប៊ានដើរចេញពីផ្ទះ។ ហើយហេតុអីបានទៅតែថាអត់មានប្រជាជនអីទៅ ឬឡានអ្នកណាស៊ីវិលអីទៅច្របូកច្របល់អត់ទេ អត់មានដាច់ខាត។

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញ លោកសាក្សី។ តើលោកដឹងទេនៅថ្ងៃនោះក៏មានមនុស្សមួយចំនួនដែលស្លៀកពាក់ជាសម្លៀកបំពាក់ស៊ីវិល ក៏ត្រូវបានគេយកទៅសម្លាប់នៅឡូលពោធិ៍ជ្រៃនោះដែរឬទេ?

[០៩:៤៣:៥៣]

**ឆ៖** ខ្ញុំអត់បានឃើញ ហើយអត់ដឹងទេ។

**ស៖** បាទ ឥឡូវនេះខ្ញុំចូលទៅដល់ខ្លឹមសារសំខាន់មួយទៀត កាលពីម្សិលមិញខ្ញុំបានសួរលោកដោយសង្ខេបៗអំពីថា តើមានមនុស្សប៉ុន្មាននាក់ជាសរុបដែលដាក់ក្នុងឡាន១៥នោះ? ខ្ញុំបានសួរសំណួរហើយតាមពិតលោកឆ្លើយថាមាន បានឃើញឡាន១៥ ហើយគឺថាឡាននីមួយៗមានមនុស្សប្រហែលជា១០, ១៥។ ហើយខ្ញុំសួរឲ្យលោកឆ្លើយមកខ្ញុំទៅតុលាការថា តើមានមនុស្សប៉ុន្មាននាក់នៅក្នុងឡានទាំង

១៥នោះ។ តើលោកនៅចាំទេ ពីសំណួរកាលម្សិលមិញនេះ?

**ឆ៖** ខ្ញុំអារឿងចាំប៉ុន្មានៗ គឺខ្ញុំគ្មានបានពិនិត្យទេ ប្រាប់អ៊ីចឹង។ ព្រោះអីឡានវាមាន១៥មែន ប៉ុន្តែវាមានដាក់តិច វាមានដាក់ច្រើនអ៊ីចឹងដែរ។ ខ្ញុំគ្មានបានទៅរាប់អីទេ មានទៅដើររាប់ អ៊ូ! ឡើងទៅលើឡានរាប់ប៉ុណ្ណេះនាក់ៗអី ខ្ញុំមិនបានរាប់ទេ ដឹងថាឡើងឡានទៅប៉ាន់ស្មានថា១៥នាក់ អ៊ីចឹងទៅឡានតូចឡានធំ ឡានធំវាច្រើនបន្តិចទៅ។

[០៩:៤៥:៣៨]

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែសំណួរពេលនោះ ហើយនិងពេលនេះ យើងប្រៀបធៀបគ្នា។ បើសិនលោកបានឃើញឡាន១៥មែន ហើយបើសិនជាឡានមួយៗមាន៣០ ទៅ៤០ ក្នុងឡាននីមួយៗថាតើសរុបទាំងអស់ដែលគេដឹកទាហានចេញពីសាលាខេត្តទៅទួលពោធិ៍ជ្រៃហ្នឹង សរុបទាំងអស់ហ្នឹងមានចំនួនប៉ុន្មាន?

ឥឡូវនេះខ្ញុំឃើញសហព្រះរាជអាជ្ញាក្រោកឈរឡើង។ សូមលោកកុំទាន់ឆ្លើយ ខ្ញុំចាំស្តាប់គាត់សិន។ ហើយប៉ុន្តែខ្ញុំសូមពន្យល់ទៅសហព្រះរាជអាជ្ញាបាទ។ ខ្ញុំនឹងសួរបន្ត។

**ប្រធានអង្គជំនុំ៖**

ជំទាស់សិន។ សាក្សីកុំទាន់អាល់ឆ្លើយតប!

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៤៦:៣០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការសួរសំណួរហ្នឹង គឺថាច្រំដែលច្រើនណាស់គឺថាគាត់បានសួរសាក្សី ជាច្រើនហើយ គឺថាមេធាវីសួរឲ្យសាក្សីឲ្យគាត់ឆ្លើយក្នុងឱកាសផ្សេងៗឱកាសច្រើនដែលធ្វើឲ្យសាក្សីហ្នឹងមានការច្រឡំភាន់ដែលគាត់មិនច្បាស់។ ហើយបើសិនជាឲ្យគាត់គណនាតាមគណិតវិទ្យាឲ្យច្បាស់អ៊ីចឹង បើសួរច្រើនដងអ៊ីចឹង ហើយឲ្យគាត់សួរឲ្យធ្វើការប៉ាន់ប្រមាណឲ្យច្បាស់ ថាឡានប៉ុន្មានមនុស្សប៉ុន្មាននោះគឺថា ហើយនិងការប៉ាន់ប្រមាណ គឺថាយើងអាចធ្វើការគណនាតាមគណិតវិទ្យាបានបើគាត់ថាមានចំនួនឡាន១៥ ហើយបើសិនជាមេធាវីនៅតែព្យាយាមសួរសំណួរឲ្យបញ្ជាក់ច្បាស់ពីសាក្សីបែបនេះជាសំណួរច្រំដែលៗ។ ដូច្នេះយើងសូមជំទាស់។

[០៩:៤៧:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ពីម្សិលមិញនេះខ្ញុំគិតថា យើងបានផ្តោតទៅលើសាក្សីអំពីសមត្ថភាពរបស់គាត់ក្នុងការគណនា។ អ្វីដែលខ្ញុំត្រឡប់មកចំណុចនេះឡើងវិញគឺដូចខាងក្រោមនេះ។ នៅពេលដែលយើងបានអានដីកាដំណោះស្រាយទាក់ទងទៅនឹងទួលពោធិ៍ជ្រៃគឺថាកថាខណ្ឌ៧០៨។ នៅក្នុងកថាខណ្ឌ៧០៨ នេះគឺបានលើកឡើង ហើយបានបង្ហាញមូលហេតុគឺថាជនជាប់ -- ជនសង្ស័យបានមកដល់សាលាខេត្តហ្នឹងគឺថាប្រហែលជាមាន៣.០០០នាក់ គឺថាបានប្រមូលផ្តុំឲ្យចូលរួមកិច្ចប្រជុំនោះ។ គឺថាភស្តុតាងតែមួយដែលយើងចៅក្រមអង្កេតបានទទួលបាននោះគឺសក្ខីកម្មរបស់គាត់ឆ្លើយទៅការិយាល័យចៅក្រមស៊ើបអង្កេត ដែលថាគាត់បានឃើញ១.០០០ ពីសាលាខេត្តចេញទៅទួលពោធិ៍ជ្រៃ។ ហើយចំនួន៣.០០០នាក់ដែលចេញពីសាក្សីនេះតែម្នាក់គត់តែប៉ុណ្ណោះ។ បើសិនជាសាក្សីផ្សេងទៀតឆ្លើយប្រហាក់ប្រហែលហ្នឹងខ្ញុំមិនរំខាននឹងសួរគាត់ទេ។ ប៉ុន្តែមានតែគាត់ម្នាក់ទេដែលថាចំណុចនេះ។ ដូច្នេះកត្តាសំខាន់បំផុតដើម្បីបង្ហាញភស្តុតាងឲ្យច្បាស់ដល់តុលាការថាតើក្រុមហ្នឹង ក្រុមជនរងគ្រោះហ្នឹងគឺ ២០០, ៣០០ ឬក៏១.០០០ ឬក៏៣.០០០ ដែលយើងចង់ឲ្យច្បាស់។ ដូច្នេះសូមលោកប្រធាន ហើយនិងលោក លោកស្រីចៅក្រមមេត្តាពិចារណាពិនិត្យមើលកថាខណ្ឌ៧០៨ នៃដីកាដំណោះស្រាយ ថាតើមានភស្តុតាងអ្វីដែលដាក់នៅក្នុងនោះបញ្ជាក់ឲ្យច្បាស់ដើម្បីយើងពិនិត្យនោះ។

[០៩:៤៩:២១]

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប។ នេះគឺជាការបកស្រាយយល់ខុសនៃអង្គហេតុនៅក្នុងដីកាដំណោះស្រាយ។ លោកមេធាវីហាក់ដូចជានិយាយមិនច្បាស់នោះទេ ប៉ុន្តែមានបុគ្គលម្នាក់ទៀតដែលបានផ្តល់សម្ភាសន៍ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដែលឆ្លើយអំពីចំនួនប៉ាន់ប្រមាណ មិនមែនមានគាត់តែម្នាក់នេះទេ ដែលពួកគេបានឃើញឡាន និងឃើញមនុស្ស។ ដូច្នេះបើសិនមេធាវីបង្ហាញថាសាក្សីនេះមានតែមនុស្សម្នាក់ដែលផ្តល់នូវការប៉ាន់ប្រមាណនោះ នេះគឺជាការឆ្លើយមិនត្រឹមត្រូវទៅតាមរបាយការណ៍លទ្ធផលនៃការស៊ើបអង្កេតនោះទេ។ ដូច្នេះអ្វីដែលសាក្សីរូបនេះបានឆ្លើយគឺជាការប៉ាន់ប្រមាណដ៏ល្អបំផុតរបស់គាត់ហើយ ហើយបើឲ្យគាត់ផ្អែកទៅលើអ្វីទូលាយជាងហ្នឹងទៀតគាត់មិនអាចធ្វើបាន។

[០៩:៥០:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យតុលាការពិនិត្យមើលកថាខណ្ឌនៃដីកាដំណោះស្រាយ ហើយមើលទៅដើងទំព័រផងដែរ គឺថាហើយសាក្សីនេះឯងដែលនិយាយថាមាន ៣.០០០ គឺថាមិនមានសាក្សីណាទៀតដែលថាចំនួនហ្នឹងមាន៣.០០០ ទេ។ នេះហើយជាមូលហេតុសំខាន់ដែលខ្ញុំជជីកសួរសាក្សីនេះឲ្យបញ្ជាក់បំភ្លឺនោះ។

[០៩:៥០:៤៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយសួរដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ចំពោះសាក្សីគឺអង្គជំនុំជម្រះយល់ឃើញថាពិតជាសំណួរច្រំដែលពិតប្រាកដ។ ដូច្នេះ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកមេធាវី កូប៉េ ថាព័ត៌មានដែលលោកសួរអំពីបញ្ហាចំនួននេះគឺយើងអង្គជំនុំជម្រះបានស្ដាប់ច្រើនហើយ ព័ត៌មានពាក់ព័ន្ធនឹងបញ្ហានេះ។ សូមលោកបន្តសំណួរផ្សេងទៀត ហើយសូមចៀសវាងនូវសំណួរច្រំដែល។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ស្របទេ យើងបានស្ដាប់សក្ខីកម្មសាក្សីតែមួយ ប៉ុន្តែសាក្សីដើមសប្ដាហ៍នោះមិនច្បាស់ដែរ ប្រហែលគាត់ថាតែ២០០ទេ។ ប៉ុន្តែហើយសាក្សីនេះបញ្ជាក់លើសពីហ្នឹង ហើយយើងមិនមានភស្តុតាងណាច្បាស់ជាងនេះទេ។ ប៉ុន្តែទោះយ៉ាងណាក្ដីខ្ញុំសូមអនុញ្ញាតបន្ត។

[០៩:៥៤:២២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីចម្លើយលោកទៅការិយាល័យចៅក្រមស៊ើបអង្កេតគឺ E3/364 ទំព័រអង់គ្លេស 0025754, ខ្មែរ 00242422, បារាំង 0028497, “នៅខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានទទួលបញ្ជាឲ្យប្រមូលទាហាន ហើយនិងប៉ូលិស ដើម្បី -- សម័យ លន់ នល់ -- ដើម្បីយកទៅសម្លាប់ចោលនៅបន្ទាយពោធិ៍ជ្រៃក្នុងស្រុកកណ្ដៀង”។ ដូច្នេះសូមលោកសាក្សី តើនៅពេលដែលលោកនិយាយថា “ខ្ញុំបានទទួលបញ្ជាឲ្យប្រមូលទាហានទាំងអស់នេះ” ខ្ញុំចង់ថា ទទួលបញ្ជាឲ្យប្រមូលយកទៅសម្លាប់នេះ តើលោក

ទទួលបញ្ជាពីអ្នកណាដើម្បីឲ្យប្រមូលពួកទាហាន ពួកប៉ូលិសទាំងអស់នោះៗ?

**ឆ៖** បាទ ទទួលបញ្ជាមកពីគណៈភូមិភាគ រហូតមកដល់តំបន់តែម្តង។

**ស៖** នៅពេលដែលលោកនិយាយថា លោកបានទទួលបញ្ជាដើម្បីប្រមូលទាហាននោះ តើលោកមានន័យថា ម៉េចទទួលបញ្ជាឲ្យប្រមូលហ្នឹង?

[០៩:៥៦:១៩]

**ឆ៖** មានថាម៉េច គេប្រាប់ថាឲ្យប្រមូលទាហានមានឋានន្តរសក្តិទៅរៀន មានន័យអីទៀត តែប៉ុណ្ណឹងឯង។

**ស៖** តើទាហានទាំងអស់នោះ គេស្ថិតនៅមួយក្រុម មួយកន្លែងគេដែរឬទេ នៅពេលដែលបន្ទាប់ពីគេចុះចូលហើយនោះ? លើកទង់ជ័យសហើយហ្នឹង តើគេនៅតែម្តុំ ឬក៏លោកទទួលបញ្ជាឲ្យប្រមូល ដោយសារគេមិននៅម្តុំ ឬយ៉ាងម៉េច? ថាតើលោកត្រូវដើរទៅប្រមូលម្នាក់ពីរនាក់មកពីកន្លែងផ្សេងយកមកដាក់ម្តុំ ឬក៏យ៉ាងម៉េច? សូមលោកពន្យល់ខ្ញុំ និងតុលាការផង។

**ឆ៖** អារឿងប្រមូលមិនចាំបាច់តែដើរអី គ្រាន់តែប្រាប់មេៗយើង ទៅប្រាប់គេថា ឧទាហរណ៍ដូចជាថា លោកហ្នឹងមេគេហ្នឹងហើយ ប្រាប់តែមេមួយហ្នឹងទៅ ថាមកជុំកន្លែងនេះៗ គេប្រាប់គ្នាគេបាត់ហើយ មិនចាំបាច់ដើរ អ្វូ មួយ ពីរ បី បួន ដប់អីណា អត់។ ប្រាប់តែមេមួយហ្នឹងថា "អឺ! លោកឯងប្រមូលពួកលោកឯងដែលមានឋានន្តរសក្តិប៉ុន្មានៗអីមកជុំគ្នា ឧទាហរណ៍ថា ប្រជុំកន្លែងខេត្តហ្នឹងទៅរួចបាត់ហើយ មិនពិបាកដើរអីទៀត។

[០៩:៥៧:៥៨]

**ស៖** ដូច្នេះ លោកខ្លួនលោកផ្ទាល់មិនបានចូលរួមនៅក្នុង -- ទៅយកទាហាន លន់ នល់ ពីកន្លែងមួយយកមកកន្លែងមួយទៀតដោយខ្លួនឯងទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អត់មានទេ។ ព្រោះអីគ្រាន់តែទៅប្រាប់តែមេគេមួយទៅ គេប្រាប់គ្នាគេបាត់ហើយ។ ហើយយើងមិនពិបាកដើប្រមូលគ្រប់កន្លែងវាឯណា។

**ស៖** តើលោកដឹងដែរឬទេថា តើទាហាន លន់ នល់ ដែលមិនស្ថិតនៅក្នុងបន្ទាយនោះត្រូវបានគេដើរប្រមូល ឬដែលថាពួកគេមិនទៅបន្ទាយ គេនៅក្នុងគ្រួសារ តើគេបានប្រមូលអ្នកទាំងអស់នោះយកទៅឲ្យប្រមូលផ្តុំដែរឬទេ?

**ឆ៖** កន្លែងពេលថ្ងៃហ្នឹង គឺទាហានអត់មានចេញទៅណាទេ ព្រោះអីមេគេប្រាប់ថា អត់មានឲ្យ

ចេញទៅណាទេ។ នៅក្នុងបន្ទាយទាំងអស់ បើឧទាហរណ៍ថាបើគេមានការអីរវល់ចាំបាច់អីវាលំបាក ហៅអីចឹង ម្ល៉ោះហើយគេមិនឲ្យកូនចៅគេទៅណាទៅណីទេ។

[០៩:៥៩:៤៥]

**ស៖** តើលោកនៅចាំដែរឬទេថា តើមានការបញ្ជាឲ្យយោធាដើរប្រមូលទាហាន លន់ នល់ ដែលនៅតាមផ្ទះ ដែលនៅសេសសល់ ដែលមិនទាន់បានយកទៅទួលពោធិ៍ជ្រៃ ក្រោយមកតើមានការបញ្ជាឲ្យយោធាដើរប្រមូលទាហាននៅតាមភូមិ នៅតាមផ្ទះដែរឬទេ?

**ឆ៖** អត់ទេ អាហ្នឹងដល់ចុងក្រោយមកទៀត គឺថាឥឡូវរំសាយតាមអង្គភាពទាហានអស់ហើយ អាហ្នឹងស្ថិតនៅលើដែលសហករណ៍ ឬមួយគណៈស្រុកឯណោះវិញទេ។ តែចំណែកទ័ពដាច់ឡែកបាត់ហើយ អាហ្នឹងគេគិតគូរខាងក្រោយទៅវិញនៅតាមសហករណ៍ឯណោះ ហើយនៅតាមស្រុកឯណោះវិញ។ ឯពួកខ្ញុំឯណោះគិតគូរនៅផ្សេងទេ ឈប់ដឹងរវីរវល់ហើយ។

**ស៖** ដូច្នេះ ខ្ញុំចង់ឲ្យច្បាស់នៅក្នុងពេលវេលា ខ្ញុំចង់និយាយអំពីរយៈពេលនៃការលើកទង់ជ័យស ឬក៏ការចាប់ទាហានលន់ នល់ ឲ្យនៅបន្ទាយ ហើយម្យ៉ាងទៀតគឺពេលវេលាដែលគេប្រជុំនៅសាលាខេត្ត តើការបញ្ជានៅក្នុងពេលហ្នឹង ថាតើមានការបញ្ជាឲ្យឆែកឆេរតាមផ្ទះ ឲ្យរកទាហានលន់ នល់ ដែលនៅតាមផ្ទះ តាមភូមិគ្រួសារដើម្បីយកមកប្រមូលផ្តុំដែរឬទេ?

[១០:០១:៣០]

**ឆ៖** អត់មានឲ្យឆែកឆេរទេ អត់។ អត់មានឲ្យឆែកឆេរដើរទៅណា ពាសវាលពាសកាល។ នៅដុបៗអីចឹងទៅ នៅតាមអង្គភាពគេទៅ បើយើងថាប្រមូលប្រាប់ទៅមេៗទៅ អត់បាច់ចាំទៅដើរពាសវាលពាសកាលឯណា អត់មានដើរឆែកឆេរ មានអីឯណាទៀត អត់។

**ស៖** តើលោកដឹងដែរឬទេនៅក្នុងពេលនោះ ចន្លោះពេលនោះឯង គេបានប្រាប់ឲ្យមនុស្សផ្សេងទៀតឲ្យមកសាលាខេត្ត គេប្រកាសតាមមេក្រូ ឧគ្ឃោសនសព្ទហ្នឹងប្រកាសឲ្យមកថា ឲ្យថាអ្នកណាជាមន្ត្រី ជាទាហាន លន់ នល់ នោះឲ្យមកសាលាខេត្ត។ តើមានគេប្រកាសអីចឹងដែរឬទេ?

**ឆ៖** មានតែគណៈភូមិភាគហ្នឹង។ គណៈភូមិភាគគេប្រកាសហើយ ប្រកាសប្រាប់ ឧទាហរណ៍ចៅហ្វាយខេត្តនៅហ្នឹង ចៅហ្វាយទៅ ចៅហ្វាយខេត្តគេប្រកាស ដែលទាហានគេបាត់ហើយ។ ហើយគេអូនៅគ្រប់កន្លែងទីតាំងគេហ្នឹង គេអូទៅប្រាប់ដល់នេះនៅត្រង់ណោះៗ មកជុំបាត់ហើយ ទៅប្រាប់តែមេហ្នឹងមួយមកទាំងអស់បាត់ហើយ។

[១០:០៣:១២]

**ស៖** អ៊ីចឹងខ្ញុំយល់ត្រូវដែរឬទេ ថាមន្ត្រីមកពីរបប លន់ នល់ គឺក្រោយពីស្ដាប់ការប្រកាសមីក្រូតាមផ្លូវរួចហើយ ពួកមន្ត្រី ពួករាជការ រដ្ឋការទាំងអស់នោះក៏បានមកប្រជុំនៅសាលាខេត្តដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បើប្រកាសមកហើយ ថាតែមកគឺមកហើយ។

**ស៖** តើលោកបានឮដែរទេនៅក្នុងប៉ុន្មានថ្ងៃនុ៎ង ឬក៏នៅថ្ងៃដែលគេប្រជុំនៅសាលាខេត្តនោះ តើអតីតទាហាន លន់ នល់ ប៉ុន្មាននាក់នៅសាលាខេត្ត ថាតើមន្ត្រីស៊ីវិល លន់ នល់ មានប្រហែលប៉ុន្មានដែលមករួមប្រជុំនៅសាលាខេត្តនៅថ្ងៃនោះ?

**ឆ៖** ខ្ញុំអត់បានពិនិត្យមន្ត្រីឯណាទេ គ្រាន់តែប្រជុំតែក្នុងអង្គប្រជុំដូចយើងអ៊ីចឹងដែរ នៅមកប្រជុំថាឥឡូវរៀបចំអីវ៉ែអីវ៉ាន់អ៊ីចឹងទៅ។ គេប្រាប់ថាប្រជុំ ថាឥឡូវថាស្អែកហ្នឹងរៀបចំ គេប្រាប់ថាទៅរៀនសូត្រអីហ្នឹង ប្រាប់តែអ៊ីចឹងមានមន្ត្រីឯណា មានប្រាប់ភ្លាមទៅភ្លាមឯណា។

**ស៖** តើលោកដឹងដែរឬទេ ថាតើនៅក្នុងពេលប្រជុំនោះ ប្រជុំនៅសាលាខេត្ត មានទាហានដែលស្លៀកពាក់ជាឯកសណ្ឋានទាហានហ្នឹង ភាគច្រើន ឬក៏អ្នកស្លៀកជនស៊ីវិលភាគច្រើន នៅពេលប្រជុំតាមដែលលោកមើលឃើញ ឬក៏ដឹងនោះ?

**ឆ៖** មានតែទាហានទេ អត់មានជនស៊ីវិលអីច្របូកច្របល់ ព្រោះអីគេបញ្ញត្តិច្បាស់លាស់ថាទាហានៗហើយ គ្មានយើងស៊ីវិលអីទៅច្របូកច្របល់ទេ យើងមានភ្នាក់ងារអីទៅរៀនហ្នឹងគេនោះ។

**ស៖** លោកសាក្សី លោកទើបតែបានឆ្លើយក្នុងសក្ខីកម្មរបស់លោក គឺថាមានប្រកាស គឺគេហៅតាមមីក្រូ តាមឧគ្ឃោសនសព្ទឲ្យមន្ត្រី អតីតរបប លន់ នល់ មកចូលប្រជុំនៅសាលាខេត្តដែរ។ តើត្រូវដែរឬទេ ដែលលោកឆ្លើយនោះ?

[១០:០៦:២៣]

**ឆ៖** ខ្ញុំឆ្លើយថា ប្រាប់តែមេគេមួយនោះទៅ ឧទាហរណ៍ថា ចៅហ្វាយខេត្តហ្នឹង ហើយប្រាប់តែចៅហ្វាយខេត្តថា ឥឡូវប្រាប់ទាហាននេះ ទាហានអីមកប្រជុំ កន្លែងខេត្តហ្នឹងទៅ។ គេ គ្នាគេ គេតែអូទៅប្រាប់បាត់ហើយ កន្លែងណាកន្លែងណី។ អាមេគេហ្នឹងតែមួយហើយ មិនបាច់ចាំទៅប្រាប់អ្នកណាទៀត។ ម៉្លោះហើយគេមកកន្លែងហ្នឹងទៅ។

**ស៖** តើធ្វើម្ដេចលោកដឹងទៅថា មិនមានជនស៊ីវិលចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ? ការប្រជុំ

នៅសាលាខេត្តនោះ ធ្វើម្តេចលោកដឹងថា មិនមានជនស៊ីវិលចូលរួមទេ?

**ឆ៖** បាទ ខ្ញុំដឹង ព្រោះអីបញ្ញត្តិច្បាស់លាស់បណ្តោយ គឺវា -- និយាយឲ្យចំ ថាផែនការគេថា គេប្រជុំទាហានទេ មិនមានជនស៊ីវិលណាមកច្របូកច្របល់ទេ។ គេនិយាយអ៊ីចឹង។ គេប្រជុំតែទាហាន ហើយយើងស៊ីវិលទៅប្រជុំអីហ្នឹងគេដែរ។ ទាល់អ្នកឯងល្ងចខោអាវទាហានទៅពាក់ ទៅប្រជុំនឹងគេ!

**ស៖** តើលោកធ្លាប់ចូលទៅក្នុងសាលាខេត្តនោះដែរឬទេនៅក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ឬនៅមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើលោកធ្លាប់ចូលក្នុងអគារសាលាខេត្តនោះដែរឬទេ?

**ឆ៖** មុនថ្ងៃ១៧ មេសា មិនទាន់ដល់ផង ខ្ញុំម៉េចបានចូល។ ទាល់តែចប់ហើយបានខ្ញុំចូល។ បើមិនទាន់ចប់មុនថ្ងៃ១៧ មេសា ខ្ញុំម៉េចបានចូល ទាហាននៅហ្នឹងមិនខ្លេខ្ញុំបាត់ហើយ។

**ស៖** ខ្ញុំយល់។ តើលោកចាំដែរឬទេ លោកចូលទៅក្នុងអគារសាលាខេត្តនោះ គឺឲ្យបានថ្ងៃដែលជាក់លាក់ហ្នឹង គឺក្រោយ១៧ មេសា ឆ្នាំ៧៥ គឺនៅថ្ងៃណាដែរ ដែលលោកចូលទៅក្នុងនុ៎ង?

[១០:០៩:១៣]

**ឆ៖** អស់រយៈ២ថ្ងៃ -- ១៧មេសា។ ១៨, ១៩ ខ្ញុំឡើងក្រុង ១៩ ចូលទៅ ចូលនោះ ខ្ញុំបង្ហួស។ ទៅគ្រាន់តែចូលភ្លាមហ្នឹងខ្ញុំបង្ហួសទៅស្រុកក្រគរបាត់ហើយ។ បានខ្ញុំត្រឡប់មកវិញ បានខ្ញុំមកឈរជើង។ គ្រាន់តែចូលមកភ្លាមហ្នឹង ឡានគេដឹកទៅក្រគរហ្នឹង។

**ស៖** លោកសាក្សី តើលោកអាចស្មានដែរឬទេ តាមលោកគិតទៅ នៅក្នុងបន្ទប់សាលាខេត្តនោះ តើលោកស្មានមើល អាចផ្ទុកមនុស្សបានប៉ុន្មាននាក់ដែរនៅក្នុងបន្ទប់ហ្នឹង តាមលោកស្មាន លោកគិតទៅមើល?

**ឆ៖** មិនដឹងបន្ទប់អីផង បន្ទប់ដូចកន្លែងស្នាក់ការគេ អត់ជាប់ប្រជុំអី មួយកន្លែងៗបើថាយកទ័ពទៅដាក់អី តែប៉ុណ្ណោះ កន្លែងណាមានទៅដាក់គ្នាប៉ុន្មាននាក់។ ទៅស្នាក់ការគេប្រជុំដូចយើងអ៊ីចឹងដែរ។ មានបន្ទប់អីដាក់ទាហានរាប់រយនាក់ហើយ។ ដូចស្នាក់ការយើងប្រជុំគ្នាអ៊ីចឹងៗអី ប្អូនដប់ម្ភៃនាក់អីអ៊ីចឹងដែរ។ ហ្នឹងនៅលើសាលាខេត្តហ្នឹង ហើយបើរង្វង់ប៉ុណ្ណឹង។

**ស៖** នៅពេលនេះ ខ្ញុំសួរជាក់លាក់តែម្តងអំពីការប្រជុំដែលពេលប្រជុំនោះបានប្រាប់អ្នកដែលចូលរួមប្រជុំថាទៅរៀនសូត្រ ហើយគេប្រាប់ថាអាចទៅជួបសម្តេចឪ។ តើលោកធ្លាប់ឮពីគេឯង ឬក៏លោកធ្លាប់ឃើញដោយខ្លួនឯងដែរឬទេថា ចំនួនមនុស្សសរុបចូលរួមទៅប្រជុំនៅថ្ងៃនុ៎ង ដែលគេប្រាប់ថាឲ្យទៅរៀនសូត្រនោះ តើលោកសរុបមកតើចំនួនមនុស្សហ្នឹងប៉ុន្មាននាក់ក្នុងពេលប្រជុំថ្ងៃនុ៎ង?

[១០:១១:៤០]

**ឆ៖** ថាខ្ញុំមិនបានសរុបទេ ខ្ញុំថាមិនបានដើររាប់ទេ មិនដឹងប៉ុន្មានៗទេ។ អ្នកណាទៅដើររាប់គេ។

**ស៖** ដើម្បីច្បាស់នោះ គឺលោកក៏មិនឮគេប្រាប់ចំនួនសរុបនៃអ្នកចូលរួមនៅទីនោះដែរ។ បានន័យថាមិនដែរឮគេប្រាប់ថា មាន១០០នាក់ ២០០នាក់ ឬក៏៣នាក់ចូលរួមប្រជុំ លោកក៏មិនដែរឮដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អត់មានអ្នកប្រាប់អីអ៊ីចេះអ៊ីចុះ។ គ្រាន់តែថាគេប្រជុំៗទៅ ខ្ញុំដើរចេញទៅកន្លែងខ្ញុំទៅ។ មានទៅបានគិតគូរអីសោះអ៊ីចឹង។ អ្នកណាមិនប្រាប់ៗហើទៅ ដើរបាត់ទៅ ទៅកន្លែងគេម៉េចៗទៅ។ ចាំតែតួនាទីថា អូ! គេចាត់តាំងឲ្យធ្វើនេះ យើងធ្វើហ្នឹងបណ្តោយ។ អូ! គេថានៅចាំកាក់ឡាន ទៅចាំកាក់ឡានទៅ។ តែប៉ុណ្ណឹង។

**ស៖** នៅពេលនេះខ្ញុំសួរត្រឡប់ទៅពេលវេលាមុនពេលហ្នឹងវិញ។ កាលពីម្សិលមិញ លោកផ្តល់សក្ខីកម្មឆ្លើយថា ការប្រជុំបានធ្វើឡើងនៅពេលនោះហើយបានសម្រេចថាទាហានលន់ នល់ ត្រូវតែយកទៅសម្លាប់ចោល។ តើលោកនៅចាំព័ត៍មានលម្អិតបន្ថែមទេដែលមេបញ្ជាការវរៈនៅពេលនោះ បានប្រាប់អំពីការណែនាំដូច្នោះនោះ? តើលោកនៅចាំ ឧទាហរណ៍ថា នៅក្នុងពេលប្រជុំនោះ តើលោកនៅចាំទេថា តើគេប្រាប់ថានឹងមានអ្វីកើតឡើងលើមេបញ្ជាការ ប៊ុល និងមេបញ្ជាការរង រុន នោះតើលោកមានដឹងព័ត៍មានបន្ថែមអ្វីទៀតដែរឬទេ?

[១០:១៣:៥៣]

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ គេនៅក្រោមឆ្ងាយ។ ជាងដី១០គីឡូម៉ែត្រឯណោះ មិនបាននៅជិតឯណា។ នៅទួលពោធិ៍ជ្រៃឯណោះ។ មិនដឹងហេតុអី ខ្ញុំអត់ដឹងតែម្តង។

**ស៖** សំណួររបស់ខ្ញុំសួរអំពីការប្រជុំ នៅពេលប្រជុំនោះ គឺគេបានសម្រេចថាអ្នកមួយចំនួនដែលត្រូវគេចោទប្រកាន់ហ្នឹង ត្រូវយកទៅសម្លាប់ចោល។ តើនៅក្នុងពេលប្រជុំហ្នឹង តើលោកបានដឹងទេ គេមានពិភាក្សា និយាយអ្វីខ្លះ គេមានប្រាប់ទេក្នុងពេលប្រជុំហ្នឹងថាលោក ប៊ុល ហើយនិងលោក រុន ដែលជាមេបញ្ជាការ និងមេបញ្ជាការរងហ្នឹងនឹងមានអ្វីកើតឡើងចំពោះគាត់? ពេលប្រជុំហ្នឹងគេមានប្រាប់ទេ?

**ឆ៖** មានប្រាប់អីយើង គេផ្សេង យើងផ្សេង។ គេទាហានមានមកប្រាប់អីពួកខ្ញុំនោះ។ ហើយខ្ញុំមិនទៅប្រាប់ពួកគេឯណា ហើយមានទៅប្រាប់ថា យកទៅបាញ់ចោលឯណា អ្នកណាទៅប្រាប់អ៊ីចឹង។

គ្រាន់តែប្រាប់ថាឲ្យទាហានមានឋានន្តរសក្តិទៅរៀនសូត្រតើ។

[១០:១៥:២៧]

**ស៖** តើលោកធ្លាប់ឮពីគេពីឯងនៅក្នុងថ្ងៃនោះ ឬក៏ថ្ងៃក្រោយៗមកទៀតមេបញ្ជាការ ប៊ុល និងមេបញ្ជាការរង រុន នោះត្រូវបានគេកាត់ក្បាល។ តើលោកមានឮទេ?

**ឆ៖** អត់ទេ ខ្ញុំអត់ដឹង។ គេនៅឆ្ងាយ ខ្ញុំប្រាប់អីចឹង ខ្ញុំចេះតែប្រាប់ថា ខ្ញុំចម្ងាយដី១០គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃមក ហើយអត់បានដឹងរឿងហេតុ។

**ស៖** តើលោកចាំដែរឬទេ លោកនិងទាហាន រួមជាមួយលោកនោះ តើលោកធ្លាប់ដឹងថាពួកគេនោះខឹងសម្បាចង់សងសឹកមេបញ្ជាការ ប៊ុល និងមេបញ្ជាការ រុន ដែរឬទេ ដោយសារតែសកម្មភាពអ្នកទាំងពីរនោះធ្លាប់បានប្រព្រឹត្តមកលើទាហានរបស់លោកមុន ១៧ មេសា ១៩៧៥នោះ?

**ឆ៖** ខ្ញុំមិនបានដឹងឆ្លើយថាស្អីទៅវិញ។ សូមបញ្ជាក់ឲ្យម្តងទៀតមក។

**ស៖** ខ្ញុំពន្យល់លោកមានភស្តុតាងប្រហែលជាអាចបង្ហាញថា មេបញ្ជាការ ប៊ុល និងមេបញ្ជាការរង រុន ត្រូវបានគេកាត់ក្បាលចោលនៅពេលនោះ ហើយប្រហែលជាមានភស្តុតាងបង្ហាញថាគេកាត់ក្បាលដោយសារតែមានអ្នកខ្លះចង់សងសឹក និងខឹងដោយសារអ្នកទាំងពីរនោះ។ តើ -- ខ្ញុំចង់សួរលោកនោះតើលោកដឹង ឬក៏លោកបានឮពីគេពីឯងនិយាយប្រាប់លោកដែលបង្ហាញថា ការដែលគេធ្វើការកាត់ក្បាលដូច្នេះ ដោយសារតែមានការសងសឹក។ តើលោកមានធ្លាប់ឮ ធ្លាប់ដឹងទេ?

[១០:១៧:៣២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សំណួរដែលមេធាវីបានចោទសួរហើយឆ្លើយអម្បាញ់មិញ គឺថាដឹកមុខសាក្សីហើយលើកជាភស្តុតាងបង្ហាញថាមានការសម្លាប់អ្នកទាំងពីរនោះ។ ដូច្នេះ ខ្ញុំខ្លួនឯងហ្នឹងមិនដឹងថាមានភស្តុតាងដែលនិយាយបង្ហាញអីចឹងទេ។ ដូច្នេះ កុំឲ្យមេធាវីដឹកមុខសាក្សី។ យើងមិនគួរធ្វើការលើកឡើងចំណុចណាមួយ ឬក៏ប្រាប់ទៅសាក្សីថាការសម្លាប់នោះដោយសារការសងសឹកនោះទេមិនជាការអ្វីនោះទេ ប្រសិនបើមេធាវីសួរទៅកាន់សាក្សីឲ្យឆ្លើយ។ ប៉ុន្តែព្យាយាមកុំលើកចម្លើយណាមួយឬបង្ហាញភស្តុតាងដឹកមុខសាក្សី។

[១០:១៨:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមធ្វើការរៀបចំសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីតើលោកធ្លាប់ឮទេនៅក្នុងថ្ងៃនោះមានទាហានធ្វើការជាមួយលោកនោះគឺធ្លាប់ឮគេថា គេចង់សងសឹក ឬមានអារម្មណ៍ចង់សងសឹកមេបញ្ជាការ ប៉ុល និងមេបញ្ជាការរង រុន ដែរឬទេ?

**លោក លឹម សាត៖**

**ឆ៖** ខ្ញុំអត់បានដឹងថា អ្នកណាចង់សងសឹកអ្នកណាទេ ខ្ញុំអត់ដឹងទេ។ រឿងគេផ្សេងព្រោះអីទាហានលន់នល់ ក៏ទាហានលោក ប៉ុល, លោក រុន ហ្នឹង ហើយមិនដឹងអ្នកណាចង់សងសឹកទៅទៀត ខ្ញុំអត់ដឹងផង ព្រោះអីខ្ញុំពួកខ្ញុំនៅផ្សេង។ អ្នកណាទៅសងសឹកៗទៅ ខ្ញុំ--រឿងគេ ខ្ញុំដោយឡែកផ្សេងម៉េចដឹងរឿងគេ។

**ស៖** លោកសាក្សីតើលោកធ្លាប់ឮ ព័ត៌មានណាមួយដែលបានបង្ហាញថា ក្រោយពេលទាហានលន់ នល់ ត្រូវបានគេយកទៅសម្លាប់ចោលនោះ ផ្ទះដែលទាហាន លន់ នល់ នោះធ្លាប់បានរស់នៅនោះក៏គេឆែកឆេរផងដែរ ហើយពេលនោះក៏មានការរឹបអូសយកទ្រព្យសម្បត្តិរបស់ទាហានលន់នល់នៅក្នុងផ្ទះនោះដែរ។ តើលោកមានធ្លាប់ឮទេ?

**ឆ៖** អត់មានឮទេ គ្រាន់តែថារៀបចំទាហានរៀនសូត្ររួច គេប្រកាសឲ្យរំសាយបាត់ហើយជម្លៀសចេញពីតាមទីក្រុងអស់ហើយ។ ទីក្រុងភ្នំពេញ ឲ្យតែទីក្រុង ពោធិ៍សាត់អីនេះបាត់អស់ហើយ។ មិនដឹងនរណាឆែកឆេររករបស់ឯណាឯណីផង។

[១០:២០:២៣]

**ស៖** តើលោកធ្លាប់ឮដែរឬទេថា នៅក្នុងអំឡុងពេលដែលទាហាន លន់ នល់ នោះចុះចាញ់នៅបន្ទាយ ហើយនៅចន្លោះពេលនុ៎ង និងមកដល់ពេលប្រជុំនៅសាលាខេត្ត គឺធ្លាប់ឮថាមានទាហាន លន់ នល់ មកពីតំបន់ផ្សេងៗ មកពីទីក្រុងភ្នំពេញ ឧទាហរណ៍អ៊ីចឹង មកពីបាត់ដំបង គេប្រមូលទាហាន លន់ នល់ ទាំងអស់នោះមកដាក់ផ្តុំនៅសាលាខេត្តដែរឬទេ? លោកធ្លាប់ឮទេ?

**ឆ៖** អត់មានទេ គឺគេដាក់នៅពោធិ៍សាត់ហ្នឹង ប្រមូលនៅពោធិ៍សាត់ហ្នឹងទៅ។ បើនៅបាត់ដំបង

គេប្រមូលបាត់ដំបង មោងប្រមូលនៅមោងហ្នឹងទៅ ហើយសូម្បីក្រគរហ្នឹងគេមិនមែននៅក្នុងពោធិ៍សាត់ដែរ ប៉ុន្តែគេប្រមូលឯហ្នឹងទៅ។ វាកាត់ជាកង់ៗអ៊ីចឹង វាដុបៗអ៊ីចឹង។ អត់មានឲ្យយកមកពីណោះមកបង្រួមគ្នាទាំងអស់ទេ តែតាម -- ត្រឹមមួយសាលាខេត្តពោធិ៍សាត់ហ្នឹង ហ្នឹងហើយតែពីត្រឹមហ្នឹងទៅៗក្រោមទៅ ឲ្យតែទីក្រុងដែលជុំវិញខេត្តហ្នឹង។ ហើយបើចេញពីខេត្តដូចថាមកស្រុកល្វា ស្រុកអីផ្សេងទៅអត់ទេ។ ហើយដូចទៅខាងស្រុកបាកានគេផ្សេងទៀតទៅ ដូចថា គេកាត់ជាកង់ៗគ្នាអ៊ីចឹង។ ទៅដល់ខេត្តបាត់ដំបងគេកាត់អ៊ីចឹងទៅ ហើយឯណាកំពង់ឆ្នាំងគេដុបៗទៅ។ មិនមែនថាមួយខេត្តហ្នឹងប្រមូលតាំងពីស្រុកបាកាន ស្រុកក្រគរមក អត់ទេ។ អាក្រគរហ្នឹងប្រមូលតាមស្រុកអ៊ីចឹងទៅ ហើយកន្លែងខេត្តបាកាន ប្រមូលតាមខេត្តអ៊ីចឹងទៅ ហើយស្រុកបាកានក៏ប្រមូលតាមស្រុកបាកានមកដែរទៅ អ៊ីចឹង។

**សៈ** លោកសាក្សីតើលោកដឹងដែរឬទេ ថាតើនៅក្នុងអំឡុងពេលទាហាន លន់ នល់ ចុះចាញ់នៅទួលពោធិ៍ជ្រៃ អំឡុងពេលហ្នឹងរហូតមកដល់ថ្ងៃប្រជុំនៅសាលាខេត្តពោធិ៍សាត់ នៅតាមផ្លូវនោះគឺគេដាក់ប៉ុស្តិ៍កុងត្រូលតាមផ្លូវលេខ៥ ត្រួតពិនិត្យអ្នកដែលធ្វើដំណើរមកពីភ្នំពេញ និងប៉ុស្តិ៍ត្រួតពិនិត្យអ្នកដែលធ្វើដំណើរមកពីខេត្តបាត់ដំបង។ តើតាមផ្លូវជាតិលេខ៥ គេមានដាក់ប៉ុស្តិ៍ឆែកអ៊ីចឹងទេ?

[១០:២២:៤៩]

**ឆៈ** អត់មានទេ គឺសន្តិភាពថ្ងៃ១៧ មេសា ក៏អត់មាន។ សូម្បីតែឡានក៏អត់មានចេញចូលដែរ។ សូម្បីតែឡានឈ្នួល ឡានពលរដ្ឋ តាក់ស៊ីអី ក៏អត់ចេញចូលឆ្វេកឆ្វាច គ្រាន់តែ គេប្រកាសឲ្យចេញចូលអីបានអាចឡានចេញចូល។ បើថាកំពុងវឹកវរអ៊ីចឹងអត់មានឡានណាចេញចូល ទាហានណាដើរបាតណាបាតណី អត់ទេ។

**សៈ** លោកសាក្សី តើដឹងដែរឬទេ ឬក៏លោកបានទទួលព័ត៌មានណាមួយដែលបង្ហាញថាទាហានលន់ នល់ ដែលយើងកំពុងតែជជែកគ្នាពេញមួយព្រឹកនេះគឺថាទាហាន លន់ នល់ ទាំងនុ៎ងគឺជាដែលឈរជើងនៅបន្ទាយទួលពោធិ៍ជ្រៃ ឬក៏ជាទាហានដែលឈរជើងនៅតាមកន្លែងផ្សេងៗនៅក្នុងខេត្តពោធិ៍សាត់។ តើលោកមានព័ត៌មានបង្ហាញអ៊ីចឹងទេ?

**ឆៈ** ខ្ញុំជម្រាបប្រាប់ថា ទាហានវាឈរជើងដោយឡែកៗពីគ្នា។ ដូចថាភូមិពោធិ៍គេឈរជើងភូមិពោធិ៍ទៅ ហើយពោធិ៍ជ្រៃ ឈរជើងពោធិ៍ជ្រៃ ឯមកលើនេះ ឯណាស្វាយបន្ទាយនោះមួយកន្លែងគ្នាហ្នឹងទៅ ហើយមកកន្លែងរំពងការ(តាមសូរស័ព្ទ) នេះគឺមួយកន្លែងគ្នាទៅ។ អ៊ីចឹងឈរជើងតាមកន្លែងតាមប៉ុស្តិ៍អ៊ីចឹង។

[១០:២៤:៣២]

**ស៖** ខ្ញុំរៀបចំសំណួរឡើងវិញលោកសាក្សី តើលោកដឹងដែរឬទេថា ទាហាន លន់ នល់ ដែលត្រូវបានគេយកទៅសម្លាប់ចោលនោះ គឺជាទាហាន លន់ នល់ ដែលគេចាប់យកមកពីតែខេត្តពោធិ៍សាត់តែប៉ុណ្ណោះ ឬក៏មកពីកន្លែងផ្សេង?

**ឆ៖** ខ្ញុំជម្រាបថា តែខេត្តពោធិ៍សាត់ហ្នឹង ខេត្តពោធិ៍សាត់ហ្នឹងហើយ។ ត្រឹមខេត្តពោធិ៍សាត់វានៅស្រុកក្រគរ ហើយស្រុកក្រគរវាឆ្ងាយ ស្រុកក្រគរគេនៅផ្សេងទៅ ហើយស្រុកបាកាននោះនៅផ្សេងទៅ។ ឯមួយទីរួមខេត្តហ្នឹង អាហ្នឹងនៅកន្លែងខេត្តនៅទៅ អត់មានច្របូកច្របល់។ អ៊ូ! ទម្រាំយកពីណោះមក១ អត់ទេ។ ទាហានមួយកន្លែងនេះ អីនោះគេយកកន្លែងនោះទៅ១ វាខុសផ្នែកគ្នាអ៊ីចឹងដែរ។

**ស៖** ខ្ញុំព្យាយាមសួរមួយបែបទៀត លោកសាក្សី ដោយសារតែប្រហែលជាលោកមិនយល់ខ្ញុំ។ ខ្ញុំព្យាយាមចង់ដឹងពីលោកនេះ តើលោកដឹងដែរឬទេថា ទាហាន លន់ នល់ ដែលគេលើកឡើងថា អ្នកទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ចោលនោះ ទាហាន លន់ នល់ ដែលត្រូវបានគេយកសម្លាប់ចោលមកតែពីបន្ទាយទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ ឬក៏ជាទាហានមកពីបន្ទាយភូមិពោធិ៍ផងដែរ?

[១០:២៦:០៦]

**ឆ៖** ខ្ញុំថាយកតាំងពីសាលាខេត្តទៅ មិនថាតែភូមិពោធិ៍ទេ យកតាំងពីសាលាខេត្តពោធិ៍សាត់នេះយកទៅបញ្ជូនទៅទាំងអស់។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោប្រធាន ខ្ញុំនឹងប្តូរប្រធានបទមួយដោយឡែកពាក់ព័ន្ធទៅនឹងការដឹងឮរបស់សាក្សី អំពីកូនក្តីរបស់ខ្ញុំ ហើយខ្ញុំគិតថា ពេលនេះជាពេលសមរម្យសម្រាប់សម្រាក ឬក៏យ៉ាងម៉េចទៀត លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការ ក្រឡាបញ្ជី សម្រាបសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៧នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាត្រូវប្រើពេល២០នាទី ឬ៣០នាទីទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីកាលពីម្សិលមិញលោកបានឆ្លើយជម្រាបតុលាការតាមរយៈសំណួររបស់មេធាវីការពារក្តីរបស់លោក នួន ជា មេធាវីជាតិនោះ។ ខ្ញុំមានសេចក្តីព្រាងប្រតិចារឹកដែលលោកឆ្លើយពីម្សិលមិញនោះគឺមិនទាន់ជាផ្លូវការទេ ប៉ុន្តែលោកបាននិយាយថា "បាទ ខ្ញុំបានឃើញមនុស្សផ្សេងទៀតទេ មិនបានឃើញ ខៀវ សំផន, អៀង សារី ទេ" គឺថាលោកថាបាន-- "ខ្ញុំបានឃើញគាត់ ឃើញលោកនួន ជា នៅខេត្តពោធិ៍សាត់ដែលគាត់ធ្វើដំណើរពីពោធិ៍សាត់ទៅបាត់ដំបង គឺនៅឆ្នាំ១៩៧៩។ ហើយគាត់មិនបានធ្វើអ្វីទេ គឺគាត់គ្រាន់តែធ្វើដំណើរតាមផ្លូវ គាត់ជិះលើឡានធ្វើដំណើរទៅខេត្តបាត់ដំបង។ យោធារបស់យើងគឺឈរជើងនៅតាមផ្លូវជាតិលេខ៥ គឺនៅខេត្តពោធិ៍សាត់នោះឯង"។ គឺថាហើយលោកថាសួរថាតើអ្នកដែលនៅលើឡានហ្នឹងពិតជា នួន ជា ឬមិន នួន ជា? លោកឆ្លើយថា "ពិតជាហ្នឹងមែន" បាទ។

លោកសាក្សី ខ្ញុំអានពីអ្វីដែលលោកបានឆ្លើយពីម្សិលមិញនោះ គឺថាលោកបានឆ្លើយបញ្ជាក់ថាលោកបានឃើញ នួន ជា – លោក នួន ជា តែម្តងទេនៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលគាត់ធ្វើដំណើរឆ្លងកាត់ខេត្តពោធិ៍សាត់។ តើត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**លោក លឹម សាត៖**

**ឆ៖** បាទត្រូវហើយ។ យោធានៅប្រចាំតាមផ្លូវជាតិលេខ៥ហ្នឹង គឺពួកអង្គភាពខ្ញុំមុនគេប្រាប់ខ្ញុំអ៊ីចឹង តែម្តងហ្នឹងតើ។

[១០:៥៤:០៤]

**ស៖** នេះជាពេលតែម្តងទេដែលលោកបានឃើញដោយភ្នែកលោកផ្ទាល់ថា បានឃើញលោក នួន ជា នោះតើអ៊ីចឹងឬទេ? ត្រឹមត្រូវទេ?

**ឆ៖** បាទ ខ្ញុំធ្វើតែម្តង ផុតហ្នឹងខ្ញុំមិនដែលបានមកជិតផ្លូវជាតិទេ។ ខ្ញុំអាលែងតែនៅខាងក្រោមផ្លូវជាតិឯណោះ។

**ស៖** បើអ៊ីចឹង លោកត្រូវតែពន្យល់មកខ្ញុំវិញដូចខាងក្រោមនេះ។ លោកក៏បានឆ្លើយផងដែរថា លោកបានឃើញ នួន ជា នៅក្នុងការប្រជុំនៅដើមឆ្នាំ១៩៧៦ នៅកន្លែងនោះដែលប្រជុំនោះគាត់និយាយប្រហែលកន្លះម៉ោង។ លោកឆ្លើយថាអ៊ីចឹង។ លោកថា គាត់និយាយពីការកសាងទំនប់ ហើយនិងជីកប្រឡាយ។ តើលោកអាចពន្យល់ ខ្ញុំបានដូចម្តេច តើអាចទៅរួចដែរឬទេ? លោកម្តងលោកឆ្លើយថាបានឃើញគាត់តែម្តងទេនៅឆ្នាំ១៩៧៩ នៅពេលគាត់ធ្វើដំណើរឆ្លងកាត់ពោធិសាត់។ ប៉ុន្តែពេលមុន លោកថាបានឃើញគាត់ម្តងទៀតនៅក្នុងការប្រជុំ។ តើលោកពន្យល់តុលាការបានម៉េច បើវាខុសគ្នាអ៊ីចឹង?

**ឆ៖** អាពេលប្រជុំវាមិនមុន អាក្រោយហ្នឹងវាផុតបាត់ហើយ ប្រជុំផ្សេងតែមុនទៅ។

**ស៖** នៅពេលដែលលោកនិយាយពីម្សិលមិញឆ្លើយទៅនឹងសំណួររបស់មេធាវីជាតិ លោកឆ្លើយថា "ខ្ញុំបានឃើញគាត់តែម្តងគត់ដែលគាត់ជិះឡានឆ្លងពោធិ៍សាត់នោះ" លោកឆ្លើយថាតែម្តងគត់ទេម្សិលមិញនោះ?

[១០:៥៦:០៧]

**ឆ៖** បាទ ខ្ញុំឃើញតែម្តងមែន មិនមែនពីរដងទេ។ អាម្តងប្រជុំផ្សេងទៅ អាឃើញឆ្លងកាត់តែម្តងក្រោយហ្នឹងទៅបាត់ហើយមានស្អីទៀត តាំងពី៧៩នោះ។

**ស៖** បាទ អ៊ីចឹងយើងត្រឡប់ទៅម្តង ពេលម្តងដែលលោកបានឃើញគាត់ដែលថា គាត់ធ្វើការពន្យល់ក្នុងអង្គប្រជុំប្រហែលកន្លះម៉ោង។ តើលោកនៅចាំទេមនុស្សដែលនៅស្តាប់គាត់នោះ ដែលវត្តមាននោះមានចំនួនប៉ុន្មាន? កន្លែងដែលលោក នួន ជា គាត់និយាយនៅក្នុងអង្គប្រជុំថាកសាងទំនប់ជីកប្រឡាយហ្នឹង បាទមានប៉ុន្មាននាក់ដែលចូលរួមស្តាប់គាត់ហ្នឹង?

**ឆ៖** អ្នកស្តាប់មានច្រើនណាស់ មិនមានតិចទេ ព្រោះអីប្រជាជនច្រើន មិនមែនបួនដប់ម្ភៃនាក់អី។ មានលើសហ្នឹង ហាហុកសិបនាក់ឯណោះ។

**ស៖** តើលោកចង់និយាយថាអ្នកដែលចូលរួមស្តាប់គាត់នោះ សុទ្ធតែជាអ្នកភូមិឬក៏ពួកអ្នកណា?

**ឆ៖** ក្រៅពីប្រជាជន អាហ្នឹងមេក្រុម មេកងអីគេតើ។ ក្រៅពីប្រជាជនគ្មាននរណាមក តែប្រជាជនមិនស្តាប់! ហើយនិងថ្នាក់មេកង មេក្រុមអីហ្នឹងស្តាប់ទៅ ស្តាប់គាត់ពន្យល់ថា "កសាង ជីកប្រឡាយ លើកទំនប់អីចឹង" គ្មានពីណាឆ្ងាយពីប្រជាជនហ្នឹង ដាក់មេកង មេក្រុមគេហ្នឹង។

**ស៖** តើលោកចង់បញ្ជាក់ច្បាស់ថា អ្នកភូមិប្រជាជនក៏មកចូលរួមផងដែរ។ តើជាការប្រជុំធំសាធារណៈដែលថាមានមនុស្សច្រើនអ្នកណាក៏ចូលរួមបាន ឬក៏ជាការប្រជុំតូចយ៉ាងដូចម្តេច? សូមលោកបញ្ជាក់បន្ថែម។

**ឆ៖** ប្រជុំតាមលទ្ធភាពដូចថាប្រជាជននៅចំនួនច្រើន ច្រើនហើយ, បើតិច តិចហើយ។

[១០:៥៨:៤៥]

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែខ្ញុំចង់និយាយជាក់លាក់តែការប្រជុំមួយដែលលោកនិយាយហ្នឹងដែលលោកនិយាយថាលោក នួន ជា និយាយកន្លះម៉ោងនោះ ហើយក្នុងនោះដែរលោកនិយាយថាប្រជាជន។ បានន័យថាអ្នកភូមិចូលរួមស្តាប់។ តើការប្រជុំមួយនេះជាការប្រជុំសាធារណៈដែលថា អ្នកណាក៏ចូលរួមស្តាប់បានជាមនុស្សច្រើន ឬក៏ជាប្រជុំរបៀបម៉េច?

**ឆ៖** ក្នុងការប្រជុំវាមានច្រើនសណ្ឋានដែរ។ អាខ្លះគេប្រជុំមីទ្ទិងនោះផ្សេង អានោះបើកកម្មវិធីដូចថា ក្នុងមន្ទីរស្រុក ឬមួយមន្ទីរខេត្ត។ នេះប្រជុំប្រជាពលរដ្ឋដែលពន្យល់ណែនាំគាត់ថា ជីកប្រឡាយលើកទំនប់អីហ្នឹងដូចប្រជុំការធម្មតា ពន្យល់ពីរឿងធ្វើការងារ។ គ្នាហាហុកសិបនាក់ក៏ប្រជុំបាន ប្រាប់ទៅ ឲ្យគាត់ប្រាប់គ្នាគាត់ត១គ្នាទៅបាត់ហើយ។អ៊ីចឹងអារឿងប្រជុំ។

[១១:០០:០៥]

**ស៖** សូមអរគុណលោកសាក្សី។ ប៉ុន្តែខ្ញុំចង់និយាយតែការប្រជុំមួយដែលលោកថា១បាននិយាយម្សិលមិញថា លោក នួន ជា បាននិយាយកន្លះម៉ោង គឺមិននិយាយប្រជុំណាទេ គឺនិយាយការប្រជុំនេះឯង។ ខ្ញុំចង់សួរលោកថា ការប្រជុំមួយនេះ តើគេអនុញ្ញាតឲ្យមនុស្សគ្រប់គ្នាចូលរួមស្តាប់បានដែរឬទេ រាប់ទាំងអ្នកភូមិជាអ្នកដែលនៅក្នុងកន្លែងនោះផងនោះ?

**ឆ៖** អារឿងប្រជុំហ្នឹង គេបើកចំហសិទ្ធិទាំងអស់ អត់មានឃាត់ឃាំងអីទេ។ គេបន់ឲ្យតែបានប្រជាជនមកច្រើន រឹតតែបានក្តាប់បានច្រើន។ អ៊ីចឹងអារឿងប្រជុំ។ បានដូចថាប្រជុំផែនការអ៊ីចឹងបានប្រជាជនមកច្រើនហ្នឹង រឹតតែល្អច្រើនហ្នឹង។ បើមកតិចថា អ្ហ៎! មិនបានដឹងគ្រប់គ្នាអីពិបាកប្រាប់តគ្នាបើចុះមកច្រើនហ្នឹង រឹតអរបានច្រើន រឹតតែល្អច្រើន។ បាទដឹងប៉ុណ្ណឹង។

[១១:០១:១៣]

**ស៖** លោកបានបញ្ជាក់ចំនួនពីមុនថា ប្រហែលជា៥០, ៦០នាក់បាទ។ ថាតើក្នុង៥០ទៅ៦០នាក់ទៅចូលរួមនោះ ជាអ្នកភូមិដែលថាមកស្ដាប់ក្នុងវគ្គដែលក្នុងប្រជុំដែលលោក នួន ជា និយាយ។ សូមលោកបញ្ជាក់បន្តិចមើល?

**ឆ៖** មកស្ដាប់ហ្នឹង ថាមកប៉ុនណាឃើញច្រើនៗហើយ។ អា៦០នាក់-- អា៥០, ៦០នាក់។ បើបានមកច្រើនរឹតតែច្រើនហើយ។ ព្រោះអីអង្គប្រជុំគេបានឲ្យតែប្រជាជនមកច្រើន អត់មានបិទសិទ្ធទេហ្នឹងប្រជុំអ៊ីចឹង។ លុះត្រាតែប្រជុំផែនការអីផ្សេងៗអីទៅ គេមិនឲ្យប្រជាជនទៅជិតទេ ដើម្បីថ្នាក់មេក្រុមមេអីហ្នឹង គេមិនឲ្យទៅជិតទេ។ ទាល់តែថ្នាក់ដឹកនាំ គេត្រឹមថ្នាក់សហករណ៍អីណោះ អាហ្នឹងគេប្រជុំផែនការអីគេផ្សេងៗ អាហ្នឹងគ្នាគេតិចទៅវិញ។ បើសិនជាប្រជុំបើកចំហអ៊ីចេះ គឺប្រជាជនទៅប៉ុន្មានក៏ទៅដែរ។ បើឲ្យស្ម័គ្រចិត្តទៅ។ គេរឹតតែអរឲ្យបានប្រជាជនទៅច្រើន។

**ស៖** ខ្ញុំយល់លោកសាក្សី។ ក៏ប៉ុន្តែខ្ញុំចង់សួរលោកថា តើលោកចាំដែរឬទេ តើក្នុងចំណោម៥០ទៅ៦០នាក់នោះ មានប៉ុន្មាននាក់ជាអ្នកភូមិ? ហើយក្នុងចំណោម៥០, ៦០នាក់នោះ មានប៉ុន្មាននាក់ជាបក្ខជន បក្សកុម្មុយនីស្តកម្ពុជា ហើយដែលមានស្លៀកសម្លៀកបំពាក់របស់គេនោះ? អ៊ីចឹងខ្ញុំចង់ឲ្យដឹងហ្នឹង គឺចង់ដឹងនោះ តើក្នុងចំណោម៥០, ៦០នាក់នោះ មានអ្នកភូមិប៉ុន្មាន ហើយអ្នកមកពីបក្សកុម្មុយនីស្តកម្ពុជាហ្នឹងប៉ុន្មាន?

[១១:០៣:១៩]

**ឆ៖** អូ! ថាប្រជាជននិងៗដែលមេកងហ្នឹងវាសម្លៀកបំពាក់ដូចតែគ្នាហ្នឹង។ គណៈសហករណ៍ក៏ដូចប្រជាជនដែរ។ អត់មានដោយឡែកទេ ព្រោះអីពួកគាត់ហ្នឹងនៅរួមគ្នាក្នុងសហករណ៍មួយៗ គ្មានសម្លៀកបំពាក់ប្លែកគ្នាណា។ តែមកសហករណ៍ ឧទាហរណ៍សហករណ៍ណា? សហករណ៍លោកអ៊ីចឹងបើសហករណ៍ហ្នឹងខ្លះមក ខ្លះអត់ខ្លះទៅ អ្នកណាទៅធ្វើការឆ្ងាយមិនបានមក អ្នកណានៅជិតមកទៅ។ អ៊ីចឹងរឿងប្រជុំ។

**ស៖** តើលោកចាំទេ ក្នុងពេលប្រជុំដែល នួន ជា និយាយប្រហែលជាកន្លះម៉ោងនោះ អ្នកភូមិដែលចូលរួមប្រជុំនោះ មានលើកជាសំណួរសួរទៅកាន់ នួន ជា វិញដែរឬទេ?

**ឆ៖** គ្មាននរណាលើកទេ។ ថាដាក់ផែនការអី ផែនការហ្នឹង។ ប្រជាជនអី គាត់អ្នកលើកអីគាត់ចាំតែស្ដាប់ហ្នឹង។ ស្ដាប់ហើយទៅបាត់ហើយ ទៅកន្លែងគាត់ហើយ គ្មានអារម្មណ៍ថា អូ! ចង់សួរនេះ

សួរនោះ។ ចុះបើផែនការថាជីកប្រឡាយ ជីកហើយ មុខតែជីកហើយ គ្មានគេចរួចទេ។ មុខតែទៅហើយ ទាំងគេទាំងខ្ញុំទៅហើយ។ បើមិនទៅម្ដេចកើត ព្រោះផែនការគេដាក់មកហើយ លើកភ្លឺស្រែ លើកទំនប់ ជីកអាងអី។ តែផែនការបន្តបន្ទាប់ ត្រូវតែទៅ ហើយមិនបាច់សំណួរសួរអីទៀតទេ ចង់សួរថាអ្ហ៊ែ! ខ្ញុំទៅធ្វើមិនរួច ព្រោះខ្វះខាតជីវភាពផង ធ្វើមិនកើតអី។ ខ្វះយ៉ាងក៏ត្រូវតែទៅដែរ អារឿងហ្នឹងអត់មានសួរដេញដោលទៀតទេ។

**ស៖** ដូច្នេះលោកសាក្សីនៅពេលដែល នួន ជា ចាប់ផ្ដើមនិយាយប្រហែលជាកន្លះម៉ោងក្នុងពេលប្រជុំនោះ តើគាត់មានណែនាំខ្លួនគាត់ដែរឬទេ? គាត់លើកឡើង ឧទាហរណ៍ថាខ្ញុំឈ្មោះ នួន ជា ខ្ញុំនឹងលើកឡើងនូវសម្ដីមួយចំនួនជូនលោក លោកស្រីស្ដាប់អ៊ីចឹង ឬក៏លោកបានដឹងតាមរយៈណាដែលថាអ្នកដែលឡើងនិយាយហ្នឹងគឺជា នួន ជា នោះ?

[១១:០៦:០១]

**ឆ៖** តាមរយៈប្រជាជនអ្នកដែលទៅប្រជុំនោះ គាត់និយាយពីអី និយាយតែពីរឿងជីកប្រឡាយអីហ្នឹង គាត់មិននិយាយរឿងអីទៀត លើកទំនប់ ប្រព័ន្ធភ្លឺស្រែអីៗអ៊ីចឹងទៅ មាននិយាយរឿងបញ្ហាអីផ្សេងៗ ហ្នឹងប្រជាជនគាត់និយាយ គាត់ប្រាប់អ៊ីចឹង។

**ស៖** ក៏ប៉ុន្តែលោក នួន ជា បាននិយាយថា អរុណសួស្ដី អស់លោក លោកស្រីទាំងអស់គ្នា ខ្ញុំឈ្មោះ នួន ជា។ គាត់មាននិយាយអ៊ីចឹងទេ?

**ឆ៖** អារឿងហ្នឹងខ្ញុំមិនបានទៅប្រជុំទេ ប្រជាជនគាត់មិននិយាយប្រាប់ដល់ខ្ញុំអ៊ីចឹងទេ គ្រាន់តែប្រាប់ថា គាត់ទៅប្រជុំ ហើយផែនការថាឲ្យជីកប្រឡាយ អារឿងនិយាយចុះៗ គាត់មិនដែលមកនិយាយប្រាប់អ៊ីចឹងទេ គ្រាន់តែប្រាប់ថា អ្ហ៎! ផែនការគេជីកប្រឡាយហើយ យើង ហ្នឹងហើយ លើកភ្លឺស្រែ លើកអីហើយមិនបាច់និយាយអ៊ីចេះអ៊ីចុះទេ គាត់បន់ឲ្យបានចប់អង្គប្រជុំ នឹងឆ្អាលប្រូច។ គាត់មិនសួររវីរវល់ គាត់កំពុងហត់ហេវសឹងអីផងហ្នឹង ស៊ីតែបបររាល់ថ្ងៃ។

[១១:០៧:៣៧]

**ស៖** ខ្ញុំដូចជាភ័ន្តភាំងហើយនេះ ខ្ញុំគិតថាលោកបាននិយាយថា លោកបានឃើញ នួន ជា ដោយផ្ទាល់ភ្នែកក្នុងពេលប្រជុំហ្នឹង ក៏ប៉ុន្តែនៅពេលនេះខ្ញុំបែរជាស្ដាប់ឮលោកនិយាយថា លោកឮពីគេទេថាគាត់ជាអ្នកណាអ្នកណីនុ៎ង។ តើអ៊ីចឹងទេ?

**ឆ៖** ថាខ្ញុំមិនបានរួមប្រជុំទេ ឃើញៗហើយ ប៉ុន្តែប្រជាជនគាត់ប្រជុំ អ៊ីចេះ។

**សៈ** ដើម្បីឲ្យខ្ញុំយល់ អាចពន្យល់បាននោះ តើធ្វើម៉េចទៅលោកដឹងថាអ្នកដែលឡើងនិយាយប្រហែលជាកន្លះម៉ោងនោះ គឺជា នួន ជា?

**ផៈ** ចុះបើឃើញហើយមិនថាម៉េច បើឃើញហើយខ្ញុំមិននៅប្រជុំណាខ្ញុំ -- បើឃើញឡើងប្រជុំហើយមិនថា ហើយដល់រឿងផែនការអីខ្ញុំមិនដឹង បើប្រជាជនប្រាប់ខ្ញុំថា ឲ្យជីកប្រឡាយ ហើយខ្ញុំមានស្ដាប់អង្គប្រជុំណា ខ្ញុំរវល់ធ្វើការងារខ្ញុំណេះ។

[១១:០៩:១៤]

**សៈ** ក៏ប៉ុន្តែសូមឲ្យលោកពន្យល់ទៅកាន់អង្គជំនុំជម្រះ។ លោកថា មិនបានចូលរួមក្នុងការប្រជុំនោះទេ ក៏ប៉ុន្តែធ្វើម្ដេចបើសិនជាលោកមិនបានប្រជុំ ដឹងថាគាត់ដែលឡើងនិយាយប្រហែលជា៣០នាទីនោះគឺជា នួន ជា ទៅ?

**ផៈ** ចុះប្រជាជនមកប្រាប់ខ្ញុំ ប្រជាជនរស់នៅជាមួយខ្ញុំ ដែលគាត់ធ្វើការដូចថាភ្ជួរស្រែ ឬមួយធ្វើអីមួយខ្ញុំ មិនប្រាប់ខ្ញុំ។ ខ្ញុំរស់នៅជាមួយប្រជាជនហ្នឹង។

**សៈ** សូមអរគុណ។ អ្នកដែលប្រាប់លោកនោះ ប្រាប់ថា នួន ជា ឡើងនិយាយប្រហែល ជាកន្លះម៉ោង ហើយអ្នកនុំង ពន្យល់ប្រាប់លោកនៅអ្វីដែលគេបានដឹងនៅពេលដែល នួន ជា ហ្នឹងឡើងនិយាយ៣០នាទី។ អ៊ីចឹងអ្នកដែលប្រាប់លោកហ្នឹង មានប្រាប់លោកថា នៅពេលដែលគាត់ឡើងនិយាយហ្នឹងគាត់បានណែនាំខ្លួនឯងដែរឬទេ អ្នកដែលឡើងនិយាយប្រហែលជា៣០នាទីហ្នឹង?

**ផៈ** គាត់និយាយអីរឿងគាត់ ណែនាំអីរឿងគាត់ គាត់មានទៅណែនាំអីខ្លួនឯងអីទេ។ គ្រាន់តែណែនាំប្រាប់ប្រជាជនធ្វើការងារតើ មានទៅនិយាយរឿងរបស់គាត់។

**សៈ** ដូច្នេះតើលោកដឹងទេថា អ្នកដែលនៅជាមួយលោកមកប្រាប់លោកថា គាត់ជា នួន ជា ហ្នឹង គឺធ្វើម៉េចទៅទើបថាគេដឹងនោះ? តើលោកដឹងទេ គេដឹងថាគាត់ហ្នឹងគឺជា នួន ជា មែនដែលឡើងនិយាយនុំង?

[១១:១១:១៩]

**ផៈ** ចុះប្រជាជន ហើយនិងទ័ពនៅក្បែរៗហ្នឹងទៀត ហើយគេមិនដឹង! សូម្បីថ្នាក់ណាក៏នៅតាមផ្លូវជាតិអីហ្នឹងតែគេ អង្គភាពទ័ពគេនៅតាមផ្លូវជាតិហើយ លោកណាៗធ្វើដំណើរអីក៏គេដឹងជាមុនដែរ។ ហ្នឹងគេ ពួកអ្នកយោធានោះ ហើយប្រជាជនបានដឹងក្រោយ។

**សៈ** លោកសាក្សី នៅដើមឆ្នាំ១៩៧៦ តើលោកដឹងទេថា តើ នួន ជា នោះកាន់កាប់មុខងារ

តួនាទីអ្វីដែរ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះអីខ្ញុំនៅអីសហករណ៍ឯណោះ។ អត់បានដឹងថា គាត់ហ្នឹងថ្នាក់ខ្ពស់ជាងខ្ញុំ ខ្ញុំជាអ្នកក្រោមអីណោះ ហើយម៉េចដឹងគាត់កាន់កាប់ស្អីៗ ខ្ញុំអត់បានដឹងទេ។ បើដឹងត្រឹមថ្នាក់តំបន់មកស្រុកអីហ្នឹងអាចដឹងខ្លះ បើដល់តែថ្នាក់មជ្ឈិមអីអ៊ីចឹង ខ្ញុំម៉េចដឹង។

[១១:១៣:០០]

**ស៖** លោកសាក្សី លោកចាំទេថា នៅពេលដែលលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតអំពីកិច្ចប្រជុំនាពេលនោះ លោកបានប្រាប់អ្នកស៊ើបអង្កេតថា លោកមិនអាចនឹកចាំឈ្មោះ នួន ជា ឡើងវិញនោះទេ។ តើលោកមាននៅចាំថា លោកបាននិយាយអ៊ីចឹងទេ ជាមួយអ្នកស៊ើបអង្កេត?

**ឆ៖** ខ្ញុំមិនដែលទេ មិនដែលនិយាយ។

**ស៖** តើលោកចាំទេ នៅពេលដែលលោកនិយាយជាមួយនឹងអ្នកស៊ើបអង្កេតនោះ អ្នកស៊ើបអង្កេតនោះបានជួយឲ្យលោកនេះស្វែងរកនឹកឃើញឈ្មោះ នួន ជា នេះឡើងវិញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ លោក កូប៉េ កំពុងតែដឹកមុខសាក្សី គាត់មានប្រតិចារឹកនៅក្នុងដៃនៃកំណត់ហេតុកិច្ចសម្ភាសន៍ហើយគាត់អាចបង្ហាញជូនបានប្រសិនបើមាន។ ប្រសិនបើមានការចោទប្រកាន់ពីមុននោះសូមលើកឡើង ក៏ប៉ុន្តែប្រតិចារឹកដែលបានលើកឡើងនេះ គឺការអះអាងថា អ្នកស៊ើបអង្កេតឡើងឡើងឈ្មោះ នួន ជា នោះ គឺដូចជាមិនត្រឹមត្រូវនោះទេ? អ្នកស៊ើបអង្កេតមិនបានលើកឡើងឈ្មោះ នួន ជា ប្រាប់ទៅសាក្សីនោះទេ។ ខ្ញុំមិនតវ៉ាទេ ក៏ប៉ុន្តែប្រសិនបើមានកំណត់ហេតុនៃការស្តាប់ចម្លើយនោះ គួរតែបង្ហាញសាក្សី ជៀសវាងកុំឲ្យមេធាវីធ្វើការដឹកមុខសាក្សី ហើយលើកឡើងចំពោះអ្វីដែលមិនបានកើតឡើងនៅក្នុងពេលស្តាប់ចម្លើយ។

[១១:១៤:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនមែនដឹកមុខទេ ខ្ញុំគ្រាន់តែសួរសាក្សីថា ចាំ ឬមិនចាំតែប៉ុណ្ណោះ? ហើយដោយសារតែពេលវេលាខ្ញុំសូមបន្តសួរទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី តើការពិតទៅលើកដំបូងដែលលោកស្តាប់ឮឈ្មោះ នួន ជា នេះគឺនៅពេលដែលគេចាប់ខ្លួន នួន ជា នៅក្នុងឆ្នាំ២០០៧នោះទេ ទើបលោកចាំផ្តើមឮឈ្មោះនួន ជា។ តើអ៊ីចឹងទេ?

**លោក លឹម សាត៖**

**ឆ៖** ឮមុនហ្នឹងទៀត។ បើចាប់ហើយ មានអ្នកណាឮទៀត។ ចាប់បាច់ហើយ អ្នកណាឃើញ! ប៉ុនឮមុននឹងចាប់ទៀត។

**ស៖** ខ្ញុំសូមសំណួរចុងក្រោយលោកសាក្សី តើជាការពិតដែរឬទេដែលថាលោក នួន ជា មិនដែលធ្លាប់ចូលរួមប្រជុំនៅក្នុងឆ្នាំ១៩៧៦ នៅខេត្តពោធិ៍សាត់ទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងមែន។ មិនដែលឃើញដែរ។

[១១:១៦:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សីដែលបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក លឹម សាត។ ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនតូចទេដើម្បីជម្រាបសួរលោកបន្ថែម។ ទាក់ទងទៅនឹងការឆ្លើយបញ្ជាក់របស់លោកកាលពីម្សិលមិញនៅពេលព្រឹកត្រង់ម៉ោង ០៩:២៦:០៨។ នៅពេលដែលមានដែលពេលដែលសួរថា “តើលោកមានស្គាល់មេដឹកនាំ នរណាខ្លះជាមេដឹកនាំចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥?” ហើយលោកបានបញ្ជាក់ថា “ខ្ញុំបានដឹងថ្នាក់ដឹកនាំជាន់ខ្ពស់មាន ខៀវ សំផន ឯអ្នកកាន់ទ័ត

នៅប្រទេសកម្ពុជាយើងតែប៉ុណ្ណោះ។ សូមលោកជួយបញ្ជាក់បន្តិចមើល៍ ថាតើលោកចង់និយាយថា -- ឯអ្នកកាន់ទ័ព លោកចង់និយាយថាជាអ្នកកាន់ទ័ព ឬមួយយ៉ាងម៉េច?

[១១:១៨:១៩]

**ឆ៖** បាទ វាអ្នកកាន់ទ័ពទទួលខុសត្រូវទ័ពហ្នឹងហើយ ដូចថាគាត់ផែនការថារៀបទ័ព ដូចថាផែនការរៀបទ័ព ទទួលថ្មីអ៊ីចឹង តាមឋានៈ តាមបន្តបន្ទាប់អ៊ីចឹង គឺផែនការរបស់ពួកគាត់ គឺគាត់មកកាន់ទ័ពទទួលខុសត្រូវខាងទ័ព។

**ស៖** បាទសូមអរគុណ។ លោកនិយាយថាអ្នកកាន់ហ្នឹង លោកដឹងថាមានតួនាទីជាអីទេក្នុងរចនាសម្ព័ន្ធយោធាហ្នឹង?

**ឆ៖** បាទ តួនាទី ដូចថាឥឡូវផែនការដាក់ទិសពីគាត់មក ដូចថាផែនការរើសម្រុកទីក្រុងកន្លែងណា កន្លែងណើ ផែនការហ្នឹង--

**ស៖** បាទ សូមកាត់លោក ដោយសារលោកអត់ឆ្លើយត្រូវនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសួរអំពីតួនាទី ឬខ្ញុំអាចបញ្ជាក់លោកថាជាឋានៈរបស់លោក ខៀវ សំផន នៅពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ ដែលតាមចម្លើយរបស់លោកថាជាអ្នកកាន់ទ័ពហ្នឹង គាត់មានតួនាទី ឬឋានៈជាអ្វីដែរនៅពេលហ្នឹង? លោកដឹងទេ?

**ឆ៖** ខ្ញុំមិនបានដឹងគាត់ឋានៈអីទេ។ ប៉ុន្តែគាត់គ្រប់គ្រងមួយប្រទេសកម្ពុជាហ្នឹងតែម្តង។

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាលោកទាក់ទងទៅនឹងការងារជាយោធារបស់លោកៗបានធ្វើកិច្ចការជាយោធាក្នុង មុនឆ្នាំ១៩៧៥ហ្នឹង រយៈពេលប៉ុន្មានឆ្នាំដែរ?

[១១:២០:១៦]

**ឆ៖** ខ្ញុំចូលធ្វើកងទ័ពឆ្នាំ១៩៧១ រហូតដល់ ៧៥។

**ស៖** បាទ សូមអរគុណ។ ចុះក្នុងឆ្នាំ៧៥ លោកមានឋានៈជាអ្វីដែរ?

**ឆ៖** ខ្ញុំឋានៈជា -- កាន់កងអនុសេនាតូច ៣០នាក់។

**ស៖** កងអនុសេនាតូច លោកអាចបញ្ជាក់ម្តងទៀតបានទេ ចំនួនសមាជិកយោធាដែលលោកគ្រប់គ្រងដែលលោកថាលោកកាន់មានចំនួនប៉ុន្មាននាក់ពិតប្រាកដ?

**ឆ៖** ៣០នាក់ ទាំងមេក្រុម មេពួកសរុបទៅវា ៣០នាក់។

**ស៖** ជារចនាសម្ព័ន្ធខាងក្រោមលោកហ្នឹង មាន១ស្អីខ្លះ លោកបញ្ជាក់មិញថាមានមេក្រុមមេពួក លោកអាចបញ្ជាក់ថា អ្នកក្រោមលោកហ្នឹងគេហៅអីគេ ឋានៈក្រោមលោក?

**ឆ៖** ខ្ញុំបញ្ជាក់ឲ្យច្បាស់ថា ឥឡូវមេក្រុមហ្នឹង កាន់១២នាក់ៗ។ ហើយ១២ នាក់ហ្នឹងគេមានមេក្រុមមួយអនុក្រុមមួយ ហ្នឹងហើយ ហើយមានមេពួកគេមួយទៀត។ មេពួកហ្នឹងគេក្ដាប់គ្នាគេ បីនាក់គ្នាគេហ្នឹង។ ហើយអ្នកពីរនាក់ហ្នឹងដែលអនុក្រុម និងប្រធានក្រុមគេក្ដាប់រួមទាំងអស់ ១២នាក់ហ្នឹង។ ដល់អាដែលបីក្រុមនោះវា៣០នាក់ បានវាបានមួយកងអនុសេនាតូច។

[១១:២២:០៦]

**ស៖** បាទ សូមអរគុណចំពោះការបញ្ជាក់នេះ។ យើងខ្ញុំសូមសួរបន្ថែមទៀត។ ថ្នាក់លើរបស់លោកមានឋានៈជាអ្វីដែរ? ថ្នាក់លើបន្ទាប់ពីលោកទៅនេះ?

**ឆ៖** ថ្នាក់លើខ្ញុំគឺអនុសេនាធំ គឺកាន់១០០នាក់។ បីនាក់គឺប្រធាន អនុប្រធាន សមាជិក គឺកាន់១០០នាក់។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ ធំជាងអនុសេនាធំដែលជាមេបន្ទាប់របស់លោកហ្នឹងជាអ្វីទៅ?

**ឆ៖** ខ្ញុំក្ដាប់អត់ទាន់បានទេ ដឹងបើថាអនុសេនាធំហើយដឹងថាអ្វីទៅ ខ្ញុំដូចមិនដឹងថាម៉េចទេ។

**ស៖** សំណួររបស់ខ្ញុំគឺអ៊ីចេះ ខ្ញុំសួរថា មេបន្ទាប់របស់លោកជាអនុសេនាធំ។ អ៊ីចឹងលើអនុសេនាធំទៀតនោះគេហៅអីគេ។

**ឆ៖** បាទ បើអ៊ីចឹងបានច្បាស់។ លើអនុសេនាធំ គេហៅវរៈ វាកាន់៣០០នាក់។ វាបីនាក់ហ្នឹងវាកាន់ ៣០០។ អាហ្នឹងបានច្បាស់។

[១១:២៣:៤៧]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឲ្យច្បាស់បានបន្តិចទៀតទេ ថាវរៈ លោកនិយាយថាវរៈហ្នឹងជាវរៈអីទៅ?

**ឆ៖** វរៈកងទ័ពណ៎ា មិនមែនវរជនឯណា វរៈកងទ័ពកាន់ទ័ពកាន់មួយវរៈ វាមាន៣០០នាក់ហ្នឹងប្រធានគេគឺ បញ្ជាការវរៈហ្នឹង។

**ស៖** បាទ លោកអាចមានបែងចែកវរៈកងទ័ពរបស់លោកហ្នឹងជាផ្នែកៗតទៀតទេ មានវរៈអីខ្លះដែលស្ថិតនៅក្នុងជួរកងទ័ពហ្នឹងណា? ក្នុងរចនាសម្ព័ន្ធកងទ័ពរបស់លោកហ្នឹង?

**ឆ៖** បាទ រឿងបែងចែក បែងចែកមានឈ្មោះៗ ហើយមិនមែនពួកខ្ញុំអ្នកដាក់ឈ្មោះឯណា ដាក់ឈ្មោះពីថ្នាក់លើដែរតើ។ ដាក់លើៗដូចថាពីថ្នាក់ភូមិភាគ។ ភូមិភាគវាដាក់ -- ឧទាហរណ៍នៅក្នុងតំបន់

ខ្ញុំ តំបន់៧ មានពីរវរសេនាតូចហ្នឹង វាមានលេខវា លេខអាវរសេនាមួយ ២០២ អាមួយ២០១។ អា២០១ គេរៀបមុនគេ។ អាហ្នឹងរាមច្បងគេ។

**ស៖** បាទៗ សូមអរគុណ។ អំមិញលោកមានប្រសាសន៍អំពីវរសេនាតូច។ អ៊ីចឹងមានន័យថា លើកងអនុសេនាធំហ្នឹងមានវរសេនាតូច។ អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយម្តងទៀត!

**ឆ៖** លើអនុសេនាធំហ្នឹង មានកងវរសេនាតូច។

**ស៖** បាទ សូមអរគុណ។ ចុះធំជាងកងវរសេនាតូចហ្នឹង ពីលើកងហ្នឹងទៀតទៅ?

**ឆ៖** អាហ្នឹង គេហៅកងពលតូចវិញ។ វាបីវរសេនាតូចហ្នឹង វាបានមួយកងពលតូច។

[១១:២៥:៥២]

**ស៖** បាទ សូមអរគុណ។ ចុះលើកងពលតូចទៀត?

**ឆ៖** លើកងពលតូច មានកងពលធំហើយ។ វាកាន់ច្រើនលើសហ្នឹងទៀតហើយ។

**ស៖** បាទ សូមអរគុណ។ ចុះមានលើកងពលធំទៀតទេ?

**ឆ៖** អត់មានទេ។

**ស៖** អ៊ីចឹងអស់ត្រឹមកងពលធំហ្នឹងហើយ?

**ឆ៖** បាទ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកដែលឮពាក្យថាអគ្គមេបញ្ជាការដែរ?

**ឆ៖** ដែលឮដែរហ្នឹង បានដឹងគេកាន់ដល់ថ្នាក់ណាទេ មិនដឹងផង។ ឮតែគេថាដែរ បើដឹងខ្ញុំដឹង ខ្លួនខ្ញុំៗរាប់រៀបបាន បើថាហួសហ្នឹង ក៏ខ្ញុំអត់ដឹង។

[១១:២៦:៥០]

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ លោកដឹង ប៉ុន្តែលោកមិនដឹងថាមានតួនាទីអី កាន់អីនោះទេ? អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងហើយ ខ្ញុំអត់ដឹងមែន មិនដឹងគាត់ថ្នាក់ខ្ពស់ហើយ ខ្ញុំអត់ដឹង។

**ស៖** បាទ សូមអរគុណ។ ត្រឡប់មកនិយាយពីលោក ខៀវ សំផន វិញ ព្រោះលោកបាននិយាយ អំពីលោក ខៀវ សំផន កាលពីម្សិលមិញ។ ខ្ញុំចង់សួរបញ្ជាក់ថា តើលោកបានឮឈ្មោះ ខៀវ សំផន នេះ

នៅពេលណា និងដោយរបៀបណាដែរ?

**ឆ៖** ឮតាមមជ្ឈិមមកធ្លាក់ដល់ភូមិភាគហ្នឹង មិនដឹង! បើគាត់ថ្នាក់លើបន្តបន្ទាប់ៗមករហូតដល់ក្រោមហើយ។ ពីលើបញ្ជាមកក្រោម ហើយពីក្រោមបន្ទាប់គាត់បញ្ជាមកក្រោមៗទៀតហើយ មកដល់ថ្នាក់ក្រោមបាត់ហើយ។

[១១:២៨:០០]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមកាន់ឲ្យខ្លី ដោយសារទី១ ខ្ញុំចង់បញ្ជាក់ថា លោកឮនៅពេលណា? បានន័យថាអាចចាំឆ្នាំក៏បានដែរ។

**ឆ៖** ឆ្នាំរៀបចំវ៉ៃទីក្រុងភ្នំពេញហ្នឹង។ ឆ្នាំ១៩៧០ -- ៧០, ៧១ ហ្នឹង។

**ស៖** បាទ អ៊ីចឹងលោកបានឮឈ្មោះ ខៀវ សំផន នេះនៅឆ្នាំ៧០ ឬ៧១ លោកបញ្ជាក់ឲ្យច្បាស់?

**ឆ៖** គឺឆ្នាំ៧១។

**ស៖** បាទ សូមអរគុណ។ លោកឮតាមរយៈនរណា ឬក៏អ្វី?

**ឆ៖** តាមរយៈពីលើមកថា ពីមជ្ឈិមមកៗដល់ភូមិភាគពាយ័ព្យហ្នឹងហើយ។ ពាយ័ព្យមកដល់តំបន់ដែរ។ វាបន្តបន្ទាប់ពីលើមក--

**ស៖** បាទ សូមៗលោកស្ដាប់សំណួរខ្ញុំ។ ខ្ញុំសូមឲ្យលោកបញ្ជាក់ អ្នកដែលលោកបានស្ដាប់ឮផ្ទាល់ពីបុគ្គលណាមួយដែលលោកបានស្ដាប់ឮ ឬក៏តាមរយៈអ្វីដែលលោកបានស្ដាប់ឮ។ អ្នកដែលៗនិយាយជាមួយលោកផ្ទាល់ ឬអ្វីដែលលោកបានឮផ្ទាល់តែម្ដង។ លោកអាចបញ្ជាក់បានទេ ថាជានរណា ឬក៏ជាអ្វី?

[១១:២៩:៤១]

**ឆ៖** បញ្ជាការវរៈខ្ញុំផ្ទាល់ហើយ។ គាត់ថ្នាក់បញ្ជាការវរៈហ្នឹង គាត់ទៅប្រជុំហើយ។ ទៅប្រជុំគាត់ដឹងផែនការពីហ្នឹងមក គាត់មិនប្រាប់មកពួកខ្ញុំខាងក្រោមទៀត! អ៊ីចឹងវាបន្តបន្ទាប់អ៊ីចឹង។

**ស៖** ដឹងថាម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** ដឹងថារៀបផែនការឆ្នាំ១៩៧១ហ្នឹងចាប់ផ្ដើមវ៉ៃចូលទៅ ដូចថាកន្លែងណាកន្លែងណី អ៊ីចឹងថារៀបចំគ្រប់កម្លាំងទាំងអស់គ្នាទៅ គ្រប់ខេត្តគ្រប់តំបន់ទៅ។

**ស៖** អ៊ីចឹងលោកដឹង សូមបញ្ជាក់ឡើងវិញ លោកដឹងនៅឆ្នាំ១៩៧១ អ៊ីចឹងមែនទេ ពីមេបញ្ជាការវរៈរបស់លោក? លោកចង់សំដៅដល់វរសេនាតូចអ៊ីចឹងមែន?

**ធ៖** បាទ។

**ស៖** បាទ សូមអរគុណ។ នៅឆ្នាំ១៩៧១ នៅពេលដែលលោកចូលភ្លាម លោកមានឋានៈជាអ្វីដែរនៅក្នុងកងយោធានោះ?

**ធ៖** ខ្ញុំឋានៈយុទ្ធជនគេនុំង។

[១១:៣១:០៦]

**ស៖** បាទ សូមអរគុណ។ ចុះកាលៈទេសៈអីដែលអាចឲ្យលោកជួបជាមួយនឹងមេបញ្ជាកងវរសេនាតូចរបស់លោកនៅពេលនោះ ដែលនិយាយអំពីលោក ខៀវ សំផន នេះ?

**ធ៖** ឪពុកខ្ញុំចុះជាប់រហូត មេខ្ញុំ តែមេកូននៅត្រង់ណា នៅត្រង់ហ្នឹងទាំងអស់គ្នា ដេកត្រង់ណាដេកត្រង់ហ្នឹងហើយ ហូបចុកទាំងអស់គ្នា ចុះសមរភូមិ សមរភូមិទាំងអស់គ្នា។ ហើយមាននៅដោយឡែកៗ ថាអ្អូ! អាងគាត់ធំធ្វើវរៈគេ ហៅមកហូបបាយមិនហូបទេ ហូបអស់ឥឡូវហ្នឹង អត់ឥឡូវហ្នឹងហើយ។ អ៊ីចឹងពួកខ្ញុំ ព្រោះអីគេប្រញាប់វ៉ៃខ្មាំង ហៅ -- បងកំពុងដេកអ៊ីចឹង -- “ថាបងឡើងហូបបាយ” តែដេកទទ្រីបទទ្រាបស៊ីអ្អែងខ្ទេចអស់ឥឡូវហ្នឹង។ ម៉្លោះហើយគាត់អ៊ីចឹង គាត់ប្រជុំប្រាប់ពួកខ្ញុំអ៊ីចឹងអ្នកណាហៅហូបបាយ មិនហូប ហូបអស់ទៅ។ ហ្នឹងគាត់បង្រៀនសូត្រអ៊ីចឹង។ ម៉្លោះហើយ--

**ស៖** បាទ សូមកាត់លោក។ តើលោកពេលដែលលោកមេបញ្ជាការរបស់លោកនិយាយពី ខៀវ សំផន ប្រាប់លោកហ្នឹង និយាយប្រាប់តែលោកម្នាក់តែម្តង ឬក៏និយាយប្រាប់អ្នកដទៃទៀតដែរ?

[១១:៣២:២៣]

**ធ៖** ប្រាប់មួយកូនចៅគាត់ទាំងអស់ហ្នឹង មិនមែនប្រាប់តែខ្ញុំណា។ កូនចៅគាត់ប៉ុន្នានគាត់ប្រជុំប្រាប់ទៅ។

**ស៖** ប្រាប់នៅក្នុងអង្គប្រជុំ ដែលលោកនិយាយអំមិញ? សូមលោកឆ្លើយម្តងទៀត។

**ធ៖** បាទ ប្រាប់អង្គប្រជុំបណ្តាយ ប្រជុំប្រាប់ផែនការ “អ្អូ! អ៊ីចេះៗ” បើមិនប្រាប់អង្គប្រជុំម៉េច ក្បួនទ័ពគេប្រាប់អង្គប្រជុំអ៊ីចឹងហើយ។

**ស៖** ប្រាប់យ៉ាងម៉េចលោកអាចបញ្ជាក់បានទេ?

**ធ៖** ប្រាប់ថាផែនការវ៉ៃខ្មាំងហ្នឹងហើយ ប្រាប់អីទៀត។ ដឹងតែប្រាប់ហើយ ប្រាប់មានអីមានតែផែនការវ៉ៃខ្មាំងហ្នឹង អត់មានក្រៅថាទៅភ្ជួរស្រែទៅអីឯណា ក្បួនទ័ពគឺវ៉ៃខ្មាំងហើយ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងប្រជុំប្រាប់ពីផែនការវ៉ៃខ្មាំង លោកឆ្លើយអំមិញ។ អ៊ីចឹងត្រឹមត្រូវ

ទេ? ហើយលោកមេបញ្ជាការរបស់លោកមានប្រាប់អីទៀតទៅលោកទេ?

[១១:៣៣:៤២]

**ឆ៖** មានប្រាប់អី ប្រាប់តែរៀបចំស្បៀង ហើយគ្រាប់រំសេវតែប៉ុណ្ណឹង មានទៅប្រាប់អីទៀត ព្រោះអីផែនការវ៉ៃហើយ។

**ស៖** ចុះនេះអំមិញលោកនិយាយអំពីលោក ខៀវ សំផន នោះអាហ្នឹងយ៉ាងម៉េចវិញទៅ? លោកមេបញ្ជាការរបស់លោកមានទំនាក់ទំនងអ្វីដែលត្រូវនិយាយអំពីលោក ខៀវ សំផន ប្រាប់លោកហើយ និងកងកម្លាំងរបស់លោកហ្នឹង -- កងកម្លាំងរបស់គាត់នោះ?

**ឆ៖** មានទំនាក់ទំនងអី គឺផែនការពីលើមកហើយ មិនបាច់ទំនាក់ទំនងអីទៀត ត្រូវតែទៅហើយ បើគេឲ្យទៅហើយមិនទៅម៉េច មិនបាច់ទំនាក់ទំនងអី។ បើថា ឧទាហរណ៍ដូចលោកអ៊ីចឹង ដល់ពេលថា ផ្ញើសំបុត្រ -- ឧទាហរណ៍ថា ផ្ញើសំបុត្រឲ្យលោកទៅ ដល់កន្លែងនេះកន្លែងនោះ មុខតែទៅហើយ។ នេះអ៊ីចឹងដែរ នេះថាផែនការថាវ៉ៃហើយ វ៉ៃហើយ មិនចាំបាច់ទំនាក់ទំនងអីទៀត។ រៀបចំ យើងរៀបចំថា យើងក្បួនទ័ពថារៀបចំ។

[១១:៣៤:៤៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ចំណុចជាក់លាក់មួយ តើលោកធ្លាប់បានចូលរួមប្រជុំជាមួយលោក ខៀវ សំផន ទេក្នុងសម័យតស៊ូពីឆ្នាំ១៩៧១ រហូតដល់ឆ្នាំ១៩៧៥? បានន័យថាមុនរំដោះភ្នំពេញ?

**ឆ៖** អត់ទេ ខ្ញុំមិនដែលទេ។ បាទ មិនដែលជួបទៀត គ្រាន់តែឮតែឈ្មោះទេ មិនដែល។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានដែលបានទទួលសំបុត្រ ឬលិខិតជាលក្ខណៈបញ្ជាពីលោក ខៀវ សំផន មកលោកដែរទេក្នុងចន្លោះពេលហ្នឹង?

**ឆ៖** អត់ដែលៗហើយ។ មិនដែលទេៗ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ។ លោក លឹម សាត ខ្ញុំសូមអរគុណ ហើយបន្តទៀតសហការីរបស់ខ្ញុំនឹងបន្តសំណួរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

[១១:៣៦:២៤]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន ជម្រាបសួរអស់លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ និងជម្រាបសួរលោក លឹម សាត។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំនឹងចោទសំណួរទៅកាន់លោកមួយចំនួនដើម្បីបន្ថែម។ ខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន ដែរ។

**សះ** អម្បាញ់មិញនេះ លោកទើបតែនិយាយពីរយៈពេលឆ្នាំ៧១ដល់៧៥ ហើយឥឡូវនេះ ខ្ញុំសូមនិយាយលើរយៈពេល៧៥, ៧៦ ដែលលោកបាននិយាយ ឬក៏លោកបានឆ្លើយទៅមេធាវីដែលបានចោទសំណួរទៅកាន់លោកមុននេះ។ សំណួរទី១របស់ខ្ញុំ គឺទាក់ទងទៅនឹងកន្លែងដែលលោកកាន់កាប់ ហើយនិងលោកទទួលខុសត្រូវនៅឃុំកណ្ដៀង អ៎! ស្រុកកណ្ដៀង។ ខ្ញុំសូមយោងទៅនឹងចម្លើយរបស់លោកដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត គឺថាឯកសារ E3/364, ជាភាសាបារាំង ERN គឺ 00282198, ERN ជាភាសាខ្មែរគឺ 00242422 ហើយជាភាសាអង់គ្លេសគឺ 00250760។

[១១:៣៧:៥០]

លោកបានឆ្លើយថា "នៅឆ្នាំ១៩៧៦ គណៈកម្មការ សុត ហើយនិងគណៈស្រុកបាកាន បានផ្លាស់ខ្ញុំពីអង្គភាពទ័ពធ្វើកងចល័តវិញក្នុងតួនាទីជាមេកងចល័ត ខ្ញុំក្ដាប់ប្រជាជននៅឃុំស្វា ស្រុកកណ្ដៀង ដែលមានប្រាប់សហករណ៍ ដោយឲ្យប្រជាជនជីកប្រឡាយ ហើយនិងលើកភ្លឺ ដោយមានបញ្ជាពីគណៈស្រុក ហើយគណៈស្រុកនោះឈ្មោះ សិត"។ នេះខ្ញុំគ្រាន់តែសូមរំឭកអំពីចម្លើយរបស់លោក។ សំណួររបស់ខ្ញុំទី១ គឺចង់ដឹងថា តើលោកអាចពន្យល់តុលាការអំពីការរៀបចំតំបន់ -- ភូមិភាគបស្ចឹម។ លោកបានឆ្លើយថាលោកបានទទួលបញ្ជាអំពីគណៈស្រុក។ តើខ្ញុំត្រូវយល់ថា គណៈស្រុកជាគណៈដែលនៅពីលើគណៈឃុំបន្តិចអ៊ីចឹងមែនទេ?

[១១:៣៨:០៩]

**លោក លឹម សាតះ**

**ឆះ** បាទ គណៈឃុំរួច បានគណៈស្រុក។

**សះ** តើមានថ្នាក់ណាមួយ គឺថាចន្លោះថ្នាក់ឃុំ ហើយនិងគណៈស្រុកនេះ មានថ្នាក់អីមួយទេ?

**ឆះ** មានថ្នាក់តំបន់។

**សះ** ហើយនៅលើគណៈតំបន់នេះមានអ្វីដែរ?

**ឆ៖** មានអ្វី គេគណៈតំបន់ហ្នឹងបណ្ដោយ។ គេៗក្ដាប់លើថ្នាក់ឃុំ ថ្នាក់ស្រុកហ្នឹង មកខាងលើហ្នឹងថ្នាក់តំបន់ហើយ មានអីទៀត។ គេក្ដាប់រួមមួយតំបន់។

**ស៖** ហើយគណៈតំបន់ហ្នឹងនៅលើគណៈតំបន់--

**អ្នកបកប្រែ៖**

លោកប្រធានខ្ញុំអត់យល់ដែរ។ គាត់និយាយ -- លោកមេធាវីប្រើពាក្យដដែល *ស៊ិកទ័រ* ហើយនិង *រ៉េស្យុង* ដូចតែគ្នាទេ។

[១១:៤០:៥៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាប្រហែលជាមានការមិនយល់ក្នុងការបកប្រែ។

**ស៖** នៅក្នុងសម្រង់នៃចម្លើយរបស់លោកដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ លោកបាននិយាយអំពីគណៈតំបន់ដែលដឹកនាំដោយ សុត។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា តើគណៈតំបន់នោះនៅពីលើគណៈ -- *ស៊ិកទ័រ* នៅគណៈតំបន់ដដែល?

ខ្ញុំនិយាយបែបផ្សេងវិញ។ ប្រហែលជាមានបញ្ហាបកប្រែ។ នៅឆ្នាំ១៩៧៦ តើសុត នេះមានតំណែងអ្វីដែរ?

**លោក លឹម សាត៖**

**ឆ៖** បាទ តាសុត ហ្នឹងគឺគណៈតំបន់ហ្នឹងហើយ។

**ស៖** ហើយ សិត ហ្នឹងគាត់នៅគណៈស្រុក។ តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចេះ លោកអត់ពិបាក ខ្ញុំរៀបរាប់។ សុត គឺដែលគណៈតំបន់ ហើយស្រុកហ្នឹងផ្សេង។ តាសុត ហ្នឹងគណៈតំបន់ទេ។

[១១:៤២:៤៩]

**ស៖** នៅឆ្នាំ៧៦ នៅពេលដែលលោកទទួលបន្ទុកប្រជាជននៅឃុំស្បាហ្នឹង តើអ្នកណាជាអ្នកបញ្ជាលោកនៅពេលនោះ?

**ឆ៖** គណៈតំបន់ហ្នឹង។ គេឋានៈលើ មិនបញ្ជាឲ្យខ្ញុំមកក្រោមនេះ។ តំបន់មកស្រុក ស្រុករួមបានមកឃុំ។ ឃុំហើយបានសហករណ៍ហ្នឹងបណ្ដោយ។

**ស៖** បើសិនខ្ញុំមិនច្រឡំទេ ទោះបីជាបញ្ជាចេញមកពីគណៈតំបន់ក៏ដោយ ក៏លោក លោកផ្ទាល់

ហ្នឹងលោកទទួលបញ្ជាគណៈស្រុកទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បន្តបន្ទាប់គ្នាអ៊ីចឹង។

**ស៖** ខ្ញុំសូមអរគុណ។ សំណួរខ្ញុំ ខ្ញុំចង់ដឹងថាលោកជួបគណៈស្រុកញឹកញាប់ប៉ុនណា ដើម្បីទទួលបញ្ជានោះ។ តើជួបរាល់ថ្ងៃ ឬក៏រាល់សប្តាហ៍? តើលោកអាចបញ្ជាក់ពីចំនួនទេ មួយសប្តាហ៍ប៉ុន្មាន មួយថ្ងៃប៉ុន្មាន ថាជួបប៉ុនណាដែរ ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** អារឿងបញ្ជាជួប។ ជួនកាលខ្ញុំទៅជួបគេ ជួនកាលគេមកជួបខ្ញុំទៅ អត់មានទៀងថា អ៊ូ! ប៉ុណ្ណេះនេះថ្ងៃ ទៅប៉ុណ្ណោះថ្ងៃអី។ ជួនកាលមួយអាទិត្យអីជួបគ្នាម្តងអីអ៊ីចឹងទៅ រវល់តែធ្វើការងារបែកគ្នាទៅ អត់មានកំណត់ថ្ងៃ។ ជួនកាលកន្លះខែអីម្តងក៏មានដែរ អ៊ីចឹង។

[១១:៤៤:៥0]

**ស៖** លោកបានឆ្លើយថា លោកនៅទទួលខុសត្រូវនៅឃុំស្យា ហើយនៅក្នុងនោះសហករណ៍៥ តើនៅក្នុងសហករណ៍មួយនោះៗមានអ្នកទទួលខុសត្រូវទេ?

**ឆ៖** បាទគេមានគណៈសហករណ៍គេ ផុតពីគណៈសហករណ៍គេមានមេកងអីគេទៀតទៅ។

**ស៖** តាមការពន្យល់របស់លោកនេះ ខ្ញុំយល់ថា លោកត្រូវបានតែងតាំងជាប្រធានមេឃុំស្យាក្នុងឋានៈជាអ្នកគ្រប់គ្រងអង្គភាពរបស់លោក។ តើនៅក្នុងថ្នាក់ស្រុក ហើយនិងថ្នាក់តំបន់នោះសុទ្ធតែមានយោធាដែលទទួលបន្ទុកដែរឬក៏យ៉ាងណា?

**ឆ៖** អត់មានទេ អត់មានយោធា។ យោធាគេផ្សេងបាត់ហើយ។ ការងារគេផ្សេង អត់មានមកជាមួយពួកខ្ញុំប្រជាជនអីទេ។

**ស៖** បាទ ដូច្នេះនៅពេលដែលលោកនិយាយថា លោកបានប្តូរពីអង្គភាពយោធាទៅអង្គភាពចល័តក្នុងឋានៈជាប្រធានអង្គភាពចល័តនេះ ពេលនោះលោកលែងជាយោធាទៀតហើយ។ តើខ្ញុំត្រូវយល់អ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំចេញពីយោធាហើយមកកងចល័តហើយមានអីនៅយោធាទៀត។

**ស៖** បាទ ក្នុងសកម្មភាពជាជនស៊ីវិលរបស់លោក តើលោកនៅតែបន្តសកម្មភាពជាជនស៊ីវិលនេះនៅក្នុងតំបន់ -- នៅក្នុងភូមិភាគបស្ចិមដដែលឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់មានដល់ភូមិភាគមជ្ឈិមទេ ខ្ញុំគិតតែក្នុងសហករណ៍ខ្ញុំស្រុកខ្ញុំតើ។ រឿងដល់មជ្ឈិមដល់ពាយ័ព្យអីអត់ផង។ អាហ្នឹងគេថ្នាក់លើឯណោះផ្សេងទៀត ខ្ញុំនៅផ្សឹង។

[១១:៤៨:០០]

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ តើនៅក្នុងរយៈពេលដែលលោកធ្វើការនៅទីនោះ អ្នកដែលលោកទាក់ទងនោះគឺថាមានតែគណៈស្រុក ហើយនិងគណៈតំបន់ទេ មានតែប៉ុណ្ណឹងទេ មែនទេ?

**ឆ៖** បាទ។

**ស៖** អ៊ីចឹងបើសិនជាលោកមិនជួបគាត់ជាប្រចាំថ្ងៃ តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថាសហករណ៍ទាំងប្រាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកនោះទទួលបញ្ជាពីលោកតែម្តង ដោយផ្ទាល់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយអត់មានអីខុសពីហ្នឹងផង។

**ស៖** ខ្ញុំនេះជាចំណុចចុងក្រោយ បន្ទាប់មកខ្ញុំសូមបញ្ចប់។ នៅក្នុងការគ្រប់គ្រងសហករណ៍ ហើយនិងរបៀបដែលប្រជាជនក្នុងសហករណ៍នោះទទួលរបបអាហារ តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងរបបអាហារនេះ?

[១១:៤៩:៣៣]

**ឆ៖** បាទ អ្នកដែលទទួលរបបអាហារហ្នឹងដូចខ្ញុំជម្រាបប្រាប់អ៊ីចឹងថាតាមអង្គភាពគេ ដែលថាតាមកងនីមួយៗអ៊ីចឹងបែកពីគ្នា មិនមែនថានៅទាំងអស់គ្នាទេ ដូចថាការដ្ឋានទី១ ទី២ តាមភូមិគេ ព្រោះអីសហករណ៍វាច្រើនគ្នា។ ម្ល៉ោះហើយដែលការដ្ឋានហូបបាយហ្នឹង វាខុសគ្នា។ ណោះផង ណោះផង វាគ្រប់កន្លែង។ ហើយមានអី មានសិទ្ធិថ្នាក់សហករណ៍ទេ គេគ្រប់គ្រងដែលក្រោយមក គឺមានពាណិជ្ជគេអ្នកដឹកជញ្ជូន ដូចថាទៅយកស្បៀង ទៅបើកពីណា ពីកន្លែងតំបន់ យកទៅដាក់អង្ករដឹកអីពីកន្លែងតំបន់កន្លែងអីហ្នឹង។ មានខ្សែខុសគ្នាអ៊ីចឹង។ អ្នកជំនាញខុសគ្នា ថាអ្នកនេះផ្នែកនេះ មានផ្នែកនោះ ប៉ុន្តែមួយរួមក្នុងសហករណ៍ដដែល។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណដែលបានឆ្លើយបញ្ជាក់។ លោកប្រធាន ខ្ញុំចប់ហើយ។ ហើយសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ សវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ។ ជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៦ ខែឧសភា ឆ្នាំ២០១៣

ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ នៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ ហ្វីលីព ស្ស៊ត ដែលនឹងត្រូវតាំងសំណួរដេញដោលដោយ ចៅក្រមនៃអង្គជំនុំជម្រះមុនភាគីដទៃទៀតនៃរឿងក្តី ហើយបន្ទាប់មកសហព្រះរាជអាជ្ញា រួមនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរយៈពេលបីវគ្គ ហើយនិងបន្ទាប់មកទៀត សហក្រុមមេធាវីការពារក្តីទាំងពីរក្រុមក៏មានរយៈពេលរួមបីវគ្គនៃថ្ងៃសវនាការដែរ ក្នុងការសួរ។ សូមភាគីពាក់ព័ន្ធនៃសំណុំរឿងក្តីនេះ និងសាធារណជនជ្រាប។

[១១:៥១:៤៨]

លោក លឹម សាត ការស្តាប់សក្ខីកម្មរបស់លោករហូតមកដល់ពេលនេះ បានចប់ហើយ ហើយវត្តមាននៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណលោក លឹម សាត ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ មកចូលរួម និងផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃកន្លះមកនេះ ដោយភាពអត់ធ្មត់អស់ពី -- និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព លទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមជូនពរលោកមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សី លឹម សាត ត្រឡប់ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមនៅក្នុងសវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទ ទី០៦ ខែឧសភា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៥៣នាទី)*